# ១០ចំណុចដែលអ្នកគួរតែដឹងពីធនាគារពិភពលោក

**មរតករយៈពេល៦០ឆ្នាំនៃធនាគារពិភពលោកអំពី**

ការឆ្លើយតបមួយចំណុចម្តងៗទៅនឹង

**១០ចំណុចដែលអ្នកមិនដែលដឹងអំពីធនាគារពិភពលោក**

តាំងពីការបើកយុទ្ធនាការ ៥០ឆ្នាំគឺគ្រប់គ្រាន់ហើយ នៅឆ្នាំ ១៩៩៤ ដើម្បីជានិមិត្តរូបនៃខួបលើកទី ៥០នៃការបង្កើតវិទ្យាស្ថានប្រេតតុនវូតនៅឆ្នាំ១៩៤៤ សង្គមស៊ីវិលនៅក្នុងពិភពលោកមានការកើនឡើងនូវសម្លេងនៅក្នុងកំណែទម្រង់ជាមូលដ្ឋាននៃធនាគារពិភពលោក និងវិទ្យាស្ថានជាបងស្រីគឺស្ថាប័នរូបិយវត្ថុអន្តរជាតិ ។ ឥឡូវនេះ ជិត១០ឆ្នាំមកហើយ បើយើងក្រឡេកមើលទៅមរតកដែលទទួលបានពីធនាគារពិភពលោក មិនត្រឹមតែនៅពេលដែលវាត្រូវបានបង្កើតឡើងកាលពីជិត៦០ឆ្នាំមុនក៏ប៉ុន្តែជាពិសេសនៅពេល១០ឆ្នាំក្រោយនេះ ត្រឡប់មកមើលការរីកចំរើនរបស់ធនាគារពិភពលោកក្នុងការដោះស្រាយបញ្ហាដែលលើកឡើងដោយសង្គមស៊ីវិលជាការឆ្លើយតបទៅនឹងគោលនយោបាយនិងកម្មវិធីរបស់ធនាគារ និងការរីកចំរើនរបស់វាឬក៏ចំណុចខ្វះខាតក្នុងការដោះស្រាយនូវការទាមទាររបស់យើង ។

បើវាយតំលៃទៅលើការបកស្រាយរបស់សៀវភៅស្តើង ដប់យ៉ាងដែលអ្នកមិនដែលដឹងអំពីធនាគារពិភពលោក ការឃោសនារបស់ធនាគារពិភពលោកបានរីកលូតលាស់ព្រមជាមួយនឹងការសងត់ធ្ងន់របស់វានៅក្នុងទំនាក់ទំនងសាធារណៈ ។ ការបោះពុម្ពផ្សាយរបស់ធនាគារពិភពលោក (លេខចេញថ្មីដែលមានដាក់នៅលើគេហទំព័ររបស់ធនាគារពិភពលោក www.worldbank.org) គឺជាការខិតខំប្រឹងប្រែងមួយរបស់ធនាគារក្នុងការធ្វើឱ្យសាធារណជនជឿជាក់ថាស្ថាប័ន ដែលជារឿយៗមានលេចលឺនូវដំនឹងស្តីពីការដាក់គោលនយោ-បាយកម្មវិធីតបកម្មសេដ្ឋកិច្ចយ៉ាងឃោរឃៅទៅលើប្រទេសដែលមានប្រជាជនងាយរងគ្រោះថ្នាក់ជាងគេនៅក្នុងពិភពលោករស់នៅឬក៏គំរោងជំលោះហិរញ្ញវត្ថុ ដែលហាក់ដូចជាបង្កឱ្យមានការបំផ្លាញដល់ប្រពន្ធ័អេកូឡូ-ស៊ីជាជាងផលប្រយោជន៏ដែលបានមកពីការអភិវឌ្ឍន៏ គឺជាការពិតកំពុងតែធ្វើការដើម្បីបង្កើនទ្រព្យសម្បត្តិដែលបានមកពីការងារល្អរបស់ពួកគេដែលភាគច្រើនគឺត្រូវគេបំភ្លេចចោល ។

ការពិត គឺមានភាពស្មុគស្មាញ ។ ដប់យ៉ាងដែលអ្នកគួរតែយល់ដឹងអំពីធនាគារពិភពលោកកែតំរូវនូវអ្វីដែលមិនពិតប្រាកដពី ១០យ៉ាងរបស់ធនាគារពិភពលោក ក៏ប៉ុន្តែសំខាន់ជាងនេះទៅទៀត សៀវភៅនេះផ្តល់ជូននូវទិដ្ឋភាពដើម្បីពន្យល់ថា ហេតុអ្វីបានជាការទាមទាររបស់ធនាគារពិភពលោកគឺកំពុងតែធ្វើឱ្យគេយល់ខុស ។ ហើយថាតើ ធនាគារពិភពលោក ចំពោះរូបភាពដែលទូលំទូលាយជាងនេះ ដើរតួនាទីជាអ្នកដឹកនាំក្នុងការបង្កើតរចនាសម្ពន្ធ័ និងថែរក្សានូវមូលដ្ឋានគ្រឹះនៃការប្រឆាំងទៅនឹងលទ្ធិប្រជាធិបតេយ្យនិងប្រពន្ធ័សេដ្ឋកិច្ចដ៏អយុត្តិធមិនៅក្នុងពិភពលោក ។

"ចំណុចជាអាទិភាពរបស់ធនាគារពិភពលោកបានផ្លាស់ប្តូរគួរឱ្យកត់សំគាល់ " វាចាប់ផ្តើមបញ្ជាក់នូវការយល់ដឹងពីការធ្វេសប្រហែសរបស់វាកាលពីអតីតកាល ។ ទោះបីជាដូច្នោះក៏ដោយ បណ្តាប្រទេសនៅអាស៊ីប៉ាស៊ីហ្វិចអាហ្វ្រិក អាមេរិចឡាទីន និងតំបន់ការីបៀន បន្តសងនូវតំលៃហិរញ្ញវត្ថុ សង្គម និងបរិស្ថានដែលបានមកពីជំងឺដែលមិននឹកស្មានដល់របស់បណ្តាគំរោងទាំងឡាយរបស់ធនាគារពិភពលោក ដែលបើគិតទៅគឺចាប់តាំងពីទស្សវត្តន៏ឆ្នាំ ១៩៥០ ។ គំរោងអគ្គិសនីគឺមិនដែលបើកដំណើរការទេ ។ គំរោងទំនប់ដែលបានធ្វើអោយប្រជាជនរាប់ពាន់នាក់ឱ្យផ្លាស់ប្តូរទីលំនៅ ដូចជាគំរោងទំនប់ Kariba នៅព្រំប្រទល់ស្សាមបៀ/ស៊ីមបាវ៉េ ។ ក្រោយពេលទំនប់បានបញ្ចប់នៅឆ្នាំ១៩៥៩ ជនរងគ្រោះដោយសារគំរោងនេះនៅតែមិនទាន់ទទួលបាននូវទឹកប្រាក់សងជំងឺចិត្តត្រឹមត្រូវនៅឡើយ តែធនាគារនៅបន្តដាក់បន្ថែមលើអំរែកនៃបំណុលដែលប្រទេសស្សាមបៀមានយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ គំរោងប្រេងឥន្ទនៈផូស៊ីល ដូចជាបំពង់បង្ហូរប្រេងនិងរ៉ែដែលបំផ្លាញនូវបរិស្ថានដែលផុយស្រួយនិងជួយជ្រោមជ្រែងដល់អំពើពុករលួយ ។ សកម្មភាពឆ្លើយតបរបស់ធនាគារពិភពលោកគឺមិនមែនជារៀបចំរចនាសម្ពន្ធ័ដើម្បីដោះស្រាយនូវការខូចខាតដែលជាលទ្ធផលនៃគំរោងនោះទេប៉ុន្តែជាសេចក្តីប្រកាសមួយដែលថាចំនុចជាអាទិភាពរបស់ធនាគារបានផ្លាស់ប្តូរហើយ ។ ការចំអកចុងក្រោយរបស់ធនាគារពិភពលោកគឺទាមទារឱ្យមានការផ្លាស់ប្តូរ ដែលមិនអាចបំរើឱ្យមានការស្រាកស្រាន្តពីទុក្ខកង្វល់សំរាប់មនុស្សរាប់ពាន់លាននាក់ដែលជាកម្មវត្ថុនៃគោលនយោបាយរបស់ធនាគារដោយសារវាមិនបានក្រោកឈរឡើងដើម្បីការពិនិត្យពិចយ័នោះទេ ។

មតិជាច្រើនដែលបានលើកឡើងនៅក្នុងការចេញផ្សាយរបស់ធនាគារពិភពលោកគឺថា ចំពោះពួកគេ វាហាក់ដូចជា ការពិត បានឆ្លុះបញ្ចាំងអំពីទស្សនៈដែលបានណែនាំដោយការតស៊ូមតិដែលថាក្រុមការងារផ្សេងៗ ដូច

ជាក្រុមពួកយើងបានធ្វើការងារនេះអស់រយៈកាល២០ឆ្នាំមកហើយ ។ ក៏ប៉ុន្តែថាតើសកម្មភាពពិតរបស់ធនាគារពិភពលោកវាត្រូវគ្នាទៅនឹងការឃោសនាលើកទឹកចិត្តរបស់វា បានគ្រោងឡើងដើម្បីបំបាត់នូវអ្នកដែលពូកែសង្ស័យជាជាងបង្ហាញនូវភាពពិតរបស់រឿងអ្វីមួយ ? ការដាក់បញ្ចូលគ្នានូវការទាមទារនិងការតាំងចិត្តដែលបានបង្ហាញនៅក្នុងដប់យ៉ាងដែលអ្នកមិនដែលដឹងពីធនាគារពិភពលោក ទៅក្នុងទិដ្ឋភាពនយោបាយរវាងធនាគារនិងបណ្តាលប្រទេសដែលដំណើរការប្រាក់កម្ចី យើងឃើញថាចំងាយរវាងការឃោសនារបស់ធនាគារពិភពលោកនិងការពិតនៅក្នុងពិភពលោកគឺមានសារសំខាន់ណាស់ក្នុងការស្វែងយល់អំពីការអភិវឌ្ឍន៍នៅលើពិភពលោក អំណាចសេដ្ឋកិច្ចនិងនយោបាយ ។

នៅទំព័របន្ទាប់ យើងឆ្លើយតបទៅនឹងចំណុចនីមួយៗដែលលើកឡើងនៅក្នុង ដប់ចំណុចដែលលោកអ្នកមិនដែលដឹងអំពីធនាគារពិភពលោក ដែលនឹងដកស្រង់ចេញមកនៅក្រោមចំណងជើង "ការឃោសនា " ជាមួយនឹងពត៌មាននៃ "ការពិត " ដែលនឹងបង្ហាញពីការសង្ស័យនៅលើរូបភាពពណ៌ផ្កាកូឡាបយ៉ាងស្រស់ ដែលធនាគារពិភពលោកដាក់ឱ្យខ្លួនគេ នឹងទិដ្ឋភាពសំខាន់ៗដទៃទៀត ។ និយាយដោយខ្លី នៅខណៈពេលដែលធនាគារបានបង្កើតឱ្យមានការរីកចំរើនដែលមានកំរិត ក្នុងការដោះស្រាយតំរូវការរបស់ប្រជាជននៅមូលដ្ឋានមនោគមន៍វិជ្ជានិងការប៉ាន់ប្រមាណជារួមរបស់ធនាគារ ទាក់ទងទៅនឹងផលប្រយោជន៍របស់សាជីវកម្មនិងការបញ្ជារបស់គោលនយោបាយដែលនៅតែបន្ត ធ្វើឱ្យខូចប្រយោជន៍នៃការតស៊ូជំនះសំរាប់រកយុត្តិធម៌ក្នុងវិស័យសេដ្ឋកិច្ច និងចិរភាពនៅក្នុងពិភពលោក ។

## ការឃោសនា

១ "ធនាគារពិភពលោកគឺជាអ្នកឧបត្ថម្ភដ៏ធំបំផុតលើការអប់រំនៅក្នុងពិភពលោក" ។

ការអប់រំគឺសំខាន់បំផុតនៅក្នុងការអភិវឌ្ឍន៍ ។ ធនាគារបានប្តេជ្ញាដាក់ប្រាក់៣៣ពាន់លានដុល្លា ដែលជាប្រាក់កម្ចីនិងឥណទានសំរាប់ការអប់រំ ហើយនាពេលថ្មីៗធនាគារបានផ្តល់ប្រាក់សំរាប់កម្មវិធីចំនួន១៥៧នៅក្នុងប្រទេសចំនួន៨៣ ។ ធនាគារបានធ្វើការយ៉ាងជិតស្និតជាមួយរដ្ឋាភិបាលក្នុងប្រទេស ភ្នាក់ងារអង្គការសហប្រជាជាតិ អ្នកផ្តល់លុយ អង្គការសង្គមស៊ីវិល និងដៃគូរការងារដទៃទៀតដើម្បីធ្វើការគាំទ្រដល់ប្រទេសកំពុងអភិវឌ្ឍន៍ នៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីឱ្យសម្រេចបាននូវគោលបំណង ការអប់រំសំរាប់អ្នកគ្រប់គ្នានៅឆ្នាំ២០១៥ ដែលកុមារទាំងអស់ជាពិសេសក្មេងស្រីនិងកុមារពិការបានចុះឈ្មោះនិងមានលទ្ធភាពបញ្ចប់បឋមសិក្សា ។

## ការពិត

**ការផ្តល់លុយរបស់ធនាគារពិភពលោកសម្រាប់ការអប់រំ ការថែរក្សាសុខភាព និងកម្មវិធីទឹកបានណែនាំអំពីការផ្តល់សេវាទាំងនោះដោយឯកជន នៅក្នុងមធ្យោបាយមួយដែលជំរុញឱ្យមានការរីកធំឡើងនូវគំលាតរវាងអ្នកមាននិងអ្នកក្រនៅក្នុងប្រទេសដែលខ្វះប្រាក់ ។ មិនតែប៉ុណ្ណោះ ប្រាក់ដែលធនាគារផ្តល់មកច្រើនតែក្នុងទម្រង់ជាប្រាក់កម្ចី"ជារូបិយបណ្ណ័" ដូចជាប្រាក់ដុល្លាអាមេរិច ដែលប្រាក់ទាំងនោះត្រូវតែសងវិញរួមជាមួយនិងការប្រាក់ ។**

ដូចដែលធនាគារពិភពលោកអួតអាង អំពីការវិភាគនៅក្នុងការអប់រំនិងការថែរក្សាសុខភាពនៅក្នុងលោកខាងត្បូង វាជាការងាយស្រួលណាស់ក្នុងការបំភ្លេចថា គ្មានទេប្រាក់ដែលឱ្យឬអំណោយសប្បុរសធម៌ តែគឺជាការវិនិយោគរបស់ធនាគារ ការវិនិយោគមួយដែលទទួលបានប្រាក់ចំណេញប្រចាំឆ្នាំ ដែលត្រូវគេហៅថា"ប្រាក់ចំណូល " ដែលច្រើនជាង១.៥ពាន់លានដុល្លា ។ ស្ទើរតែគ្រប់កម្មវិធីទាំងអស់ដែលលើកឡើងនៅក្នុង១០ចំណុចដែលអ្នកមិនដែលដឹងអំពីធនាគារពិភពលោក ទាក់ទងទៅនឹងប្រាក់កម្ចីដែលរដ្ឋាភិបាលទទួលប្រាក់កម្ចី

មិនទំនងជាមានលទ្ធភាពក្នុងការសងប្រាក់កម្ចីវិញទេជារូបិយបណ្ណ័ តែបង្កើននូវទម្ងន់នៃបំណុលដែលមិនអាចទ្រាំទ្ររួច ។

ករណីនៃការផ្លាស់ប្តូរចេញពីប្រាក់កម្ចីទៅជាប្រាក់ដែលសំរេចឱ្យ ត្រូវបានធ្វើឡើងដោយអ្នកសេដ្ឋកិច្ចនៃការអភិវឌ្ឍន៍និងអង្គការក្រៅរដ្ឋាភិបាលជាច្រើនទសវត្សមកហើយ ។ នៅក្នុងការលើកឡើងនៃទីស្នាក់ការកណ្តាលធនាគារពិភពលោកនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ ២០០១ ប្រធានាធិបតីសហរដ្ឋអាមេរិច George W. Bush បានស្នើ "រហូតដល់៥០% នៃប្រាក់ជំនួយដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍សំរាប់ប្រទេសដែលក្រីក្របំផុតត្រូវផ្តល់ឱ្យក្នុងលក្ខណៈជាប្រាក់ផ្តល់ឱ្យសំរាប់ការអប់រំ សុខភាព ចំណីអាហារ ការផ្គត់ផ្គង់ទឹក អនាម័យនិងតម្រូវការដទៃទៀតរបស់មនុស្ស" ។ ធនាគារពិភពលោកមានការរួញរាទៅនឹងសំណើរលុយដែលត្រូវផ្តល់ឱ្យ ហើយតវ៉ាថា សំណើរនេះនឹងរារាំងសមត្ថភាពរបស់ធនាគារក្នុងការគាំទ្រនូវការឈានទៅមុខដែលធនាគារបានបង្កើតឡើងនៅក្នុងកម្មវិធីប្រាក់កម្ចីរបស់ធនាគារ ។ សំណើរដែលចង់ឱ្យមានការផ្លាស់ប្តូរពីប្រាក់កម្ចីទៅជាជំនួយឥតសំណង គឺជាជំហានក្នុងទិសដៅដ៏ត្រឹមត្រូវ ក៏ប៉ុន្តែ "សំរាប់សំណើរដើម្បីសំរេចនូវការស្តារឡើងវិញនូវអធិបតេយ្យភាពសេដ្ឋកិច្ច...ដែលចាំបាច់ទូទាំងលោកខាងត្បូងគឺវាត្រូវតែបដិសេដន៏ចោលនូវលក្ខខណ្ឌ៏ផ្សេងៗទៅលើជំនួយឥតសំណង ភ្ជាប់ទៅនឹងការលុបចោល១០០%នូវបំណុលរបស់ប្រទេសនីមួយៗចំពោះស្ថាប័នពហុភាគីផ្សេងៗ ហើយបង្កើននូវការផ្លាស់ប្តូរពីប្រាក់កម្ចីទៅជាជំនួយឥតសំណងដែលហួសពីការជ្រើសរើសតាមតែអំពើចិត្តរបស់ Bush នៅក្នុងកំរិត៥០%" -ឬកំរិត ១៨-២២% ដែលយល់ព្រមនៅក្នុងការសំរបជាមួយសហគមន៍អឺរ៉ុបបន្ទាប់ពីមានការចរចារពន្យាពេល ។

បញ្ហាចំបងនោះគឺភវនីយភាព ដែលជំនួយឥតសំណងនឹងត្រូវប្រើដើម្បីជាប្រាក់ជំនួយដល់សាជីវកម្មផ្សេងៗដែលពួកគេបានកេងយកផលប្រយោជន៍ពីការផ្តើមគំនិតផ្សេងៗរបស់ធនាគាពិលោកក្នុងការធ្វើឯកជនលើការផ្តល់សេវាសាធារណៈផ្សេងៗនៅក្នុងប្រទេសដែលក្រីក្របំផុតខ្លះនៅក្នុងពិភពលោក ឱកាសមួយដែលធ្វើឱ្យមានភាពស្មុគស្មាញដោយសារមានអតិថិជនភាគច្រើន ដែលក្រីក្របំផុតមិនអាចបង់ថ្លៃក្នុងកំរិតនៃប្រាក់ចំណេញ ប៉ុន្តែអាទិភាពដ៏ធំ( អតិថិជនដែលមានលទ្ធភាពបង់ប្រាក់) មាននៅក្នុងសហរដ្ឋអាមេរិច ។

ជាផ្នែកមួយនៃកម្មវិធីកំណែទម្រង់រចនាសម្ព័ន្ធ (SAPs) នាពេលថ្មីៗនេះត្រូវបានចាត់ជាឥណទានដើម្បីគាំទ្រការកាត់បន្ថយភាពក្រីក្រ ដែលក្នុងចំណោមការងារជាច្រើនគឺខំកាត់បន្ថយចំណាយរបស់រដ្ឋាភិបាល និងទុកប្រាក់ដើម្បីសងបំណុលធនាគារពិភពលោករហូតមកទល់នឹងពេលថ្មីៗនេះ បានលើកទឹកចិត្តអតិថិជនត្រូវបង់ប្រាក់សំរាប់សាលារៀនសាធារណៈដែលកាលពីមុនមិនបាច់បង់ប្រាក់ ។ នៅក្នុងប្រទេសនីមួយៗ ដែលបង្កើតកម្មវិធីអតិថិជនត្រូវបង់ប្រាក់ គ្រួសារក្រីក្របានស្វែងយល់ថាពួកគេមិនមានលទ្ធភាពបង់ថ្លៃសាលាឱ្យកូនរបស់ពួកគេរៀនឡើយ ហើយការចុះឈ្មោះចូលរៀនមានការធ្លាក់ចុះជាពិសេសសំរាប់ក្មេងស្រី ។ ការធ្លាក់ចុះនៅក្នុងអនក្ខរភាព ចំនួននិងការបញ្ចប់ការសិក្សាក៏ធ្លាក់ចុះតាមនោះដែរ ។

នៅខែកញ្ញា ឆ្នាំ ២០០១ ប៉ុន្មានឆ្នាំក្រោយពីការតវ៉ារបស់ប្រជាជនមូលដ្ឋាននិងការកើនឡើងនូវភស្តុតាងដែលបង្ហាញពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការអប់រំត្រូវបង់ប្រាក់ដោយអ្នកសិក្សា នៅទីបំផុតធនាគារពិភពលោកបានយល់ព្រមបញ្ឈប់ការលើកទឹកចិត្តឱ្យអ្នកសិក្សាត្រូវបង់ប្រាក់សំរាប់បឋមសិក្សា ។ ការផ្លាស់ប្តូរនេះយ៉ាងហោចណាស់ជាការឆ្លើយតបមួយផ្នែកទៅនឹងច្បាប់ដែលបានអនុម័តកាលពីឆ្នាំមុនដោយសភាអាមេរិច ដែលតំរូវឱ្យអ្នកតំណាងអាមេរិចប្រចាំវិទ្យាស្ថានពហុភាគី ដើម្បីធ្វើការប្រឆាំងលើកម្មវិធីផ្សេងៗដែលអតិថិជនត្រូវបង់ប្រាក់ ។ ការផ្លាស់ប្តូរ ខណៈដែលមានការស្វាគមន៍ មិនបានដោះស្រាយនូវអន្តរាយជាច្រើនឆ្នាំដែលធ្វើឡើងដោយកម្មវិធីអតិថិជនត្រូវបង់ប្រាក់ និងវិធានការដ៏គ្រៀមក្រោះដទៃទៀតនោះឡើយ ។ មានតែការលុបចោលបំណុលដោយគ្មានលក្ខខណ្ឌនិងសំណងផ្សេងៗតែប៉ុណ្ណោះត្រូវធ្វើ ។ កម្មវិធីអតិថិជនត្រូវបង់ប្រាក់បានបង្កើតឡើងនៅក្រោមកម្មវិធីកំណែទម្រង់មុនៗ ដែលនៅតែមាននៅក្នុងករណីជាច្រើន ហើយទោះបីជាធនាគារពិភពលោកបានផ្លាស់ប្តូរគោលនយោបាយជាច្រើនលើការអប់រំ ដែលអ្នកសិក្សាត្រូវបង់ប្រាក់ហើយទទួចឱ្យពួកគេគោរពគោលការនេះក៏ដោយ កម្មវិធីកំណែទម្រង់នេះនៅតែតំរូវឱ្យកាត់ថវិកាយ៉ាងច្រើនដែលធ្វើឱ្យរដ្ឋាភិបាលនៅមានឧបាស្រ័យដ៏តិចតួចជាជាងវិធានការ ដែលតំរូវឱ្យប្រមូលធនធានពីប្រជាពលរដ្ឋដែលទីទ័លក្របំផុត ។

ធនាគារពិភពលោកមានប្រវត្តិជាច្រើនឆ្នាំនៃការលើកទឹកចិត្តលើកម្មវិធីអតិថិជនត្រូវបង់ប្រាក់ឬក៏បង្កើនប្រាក់ឈ្នួលសាលា នៅថ្នាក់វិទ្យាល័យនិងមហាវិទ្យាល័យផងដែរ ។ ជាឧទាហរណ៍មួយ នៅឆ្នាំ១៩៩៩ រវាងប្រធា-នាធិបតីបន្ទាប់របស់ប្រទេសមិចស៊ិច Eanesto Zedilloនិងធនាគារពិភពលោក ដែលបានបញ្ចប់នូវប្រពៃណី

រាប់ទសវត្សនៃការអប់រំកំរិតខ្ពស់ដែលមិនបង់ប្រាក់នៅសកលវិទ្យាល័យស្វយភាពជាតិនៅទីក្រុងមិចស៊ិកូ ។ កូដកម្មដែលប្រកាសឡើងដោយសាស្ត្រាចារ្យនិងនិស្សិតដើម្បីតវ៉ាការបង្ខំឱ្យប្រើប្រព័ន្ធអ្នកសិក្សាត្រូវបង់ប្រាក់និងកំណែទម្រង់រចនាសម្ពន្ធ័ផ្សេងៗទៀត ត្រូវបានពន្យាពេលដោយសារការស្នាក់ស្ទើររបស់រដ្ឋាភិបាលក្នុងការដាក់ប្រាក់កម្ចីរបស់គេនៅក្នុងការប្រជុំប្រថានដោយបំពានរបស់ធនាគារពិភពលោក ។

## ការឃោសនា

**២** **"ធនាគារពិភពលោកគឺជាអ្នកផ្តល់លុយលើកម្មវិធីប្រឆាំងនឹង HIV/AIDS ដ៏ធំបំផុតនៅលើពិភពលោក**

រៀងរាល់ថ្ងៃ មានប្រជាជន១៤.០០០បន្ថែមទៀតដែលបានឆ្លងមេរោគហ៊ីវ ។ ពាក់កណ្តាលនៃពួកគេទាំងនោះមានអាយុពី ១៥-២៤ឆ្នាំ ។ HV/AIDS គឺកំពុងតែធ្វើឱ្យកំណើនសេដ្ឋកិច្ចសង្គមដែលទទួលបានកាលពី៥០ឆ្នាំមុនរបស់ប្រទេសកំពុងអភិវឌ្ឍន៍ដើរថយក្រោយវិញ ។ ក្នុងនាមជាសហឧបត្ថម្ភរបស់UNAIDS -ដែលសហការលើការឆ្លើយតបជាសកលទៅលើការឆ្លងរាលដាល- ធនាគារពិភពលោកបានប្តេជ្ញាផ្តល់ជាង១.៦ពាន់លានដុល្លាដើម្បីធ្វើការប្រឆាំងនឹងការរីករាលដាលនៃជំងឺអេដស៍នៅជុំវិញពិភពលោក ។ ធនាគារបានសន្យាថា គ្មានប្រទេសណាមួយដែលមានយុទ្ធសាស្ត្របង្ការHIV/AIDSមានប្រសិទ្ធភាព អនុវត្តយុទ្ធសាស្ត្រដោយគ្មានជំនួយនោះឡើយ ហើយក្នុងភាពជាដៃគូររវាងធនាគារជាមួយរដ្ឋាភិបាលនៅទ្វីបអាហ្វ្រិក បានបើកយុទ្ធនាការកម្មវិធីពហុប្រទេសHIV/AIDS(MAP) ដែលបង្កើតធនធានដ៏សំខាន់ដើម្បីធ្វើឱ្យអង្គការសង្គមស៊ីវិលនិងសហគមន៍អាចរកបានដោយងាយ ។ ប្រទេសជាច្រើនបានអភិវឌ្ឍយុទ្ធសាស្ត្រHIV/AIDSថ្មីៗ ដែលបច្ចុប្បន្ននេះ ប្រទេសផ្សេងទៀតកំពុងតែរៀនសូត្រពីយុទ្ធសាស្ត្រទាំងនោះ ហើយសំរួលទៅតាមលក្ខខណ្ឌមូលដ្ឋាន ។ នៅឆ្នាំ២០០២ MAP បានផ្តល់ថវិកាមួយពាន់លានដុល្លាដើម្បីជួយប្រទេសជាច្រើននៅអាហ្វ្រិកពង្រីកកម្មវិធីបង្ការ ថែទាំនិងព្យាបាលថ្នាក់ជាតិរបស់ពួកគេ ។

## ការពិត

**ដូចដែលធនាគារពិភពលោកបានបង្ខំប្រទេសដែលខ្ចីប្រាក់ ឱ្យអនុវត្តកម្មវិធីកំណែទម្រង់ហេដ្ឋារចនាសម្ពន្ធ័ កម្មវិធីនេះបានធ្វើឱ្យអន្តរាយដល់សកម្មភាពប្រឆាំងនឹង HIV/AIDS ។**

កម្មវិធីកំណែទម្រង់ហេដ្ឋារចនាសម្ពន្ធ័ (SAP) បានធ្វើឱ្យគាំង/ខូចគុណភាពនៃប្រពន្ធ័ថែរក្សាសុខភាព ជាពិសេសនៅអាហ្វ្រិកកំឡុងទសវត្សរ៍៨០និង៩០ ជាការរៀបចំឆាកមួយសំរាប់មហន្តរាយនៃការឆ្លងរីករាលដាលដ៏មហិមានៃHIV/AIDS ។ ក្រោយពេលដែលប្រទេសកេនយ៉ាបានគោរពតាមការដឹកនាំផ្តាច់ការរបស់ធនាគារពិភពលោកដោយចាប់ផ្តើមគិតលុយ ២.១៥ ដុល្លាសំរាប់ការទៅជួបពេទ្យនៅគ្លីនិកសុខភាពលើជំងឺអេដស៍

ម្តង ចំនួនអ្នកជំងឺដែលត្រូវទទួលសេវាបានធ្លាក់ចុះពី ៣៥-៦០% ។ គំរូនេះបានកើតមាននៅទូទាំងទ្វីបអាហ្វ្រិក អាមេរិចឡាទីន និង អាស៊ី ។

វេជ្ជបណ្ឌិត Peter Lurie នៃ Public Citizen ក៏បានលើកឡើងដោយមានការជឿទុកចិត្តនៅក្នុងទស្សនាវដ្តីជំងឺអេដស៍ថា គោលនយោបាយកំណែទម្រង់ហេដ្ឋារចនាសម្ព័ន្ធ ដែលបង្កើតឡើងដោយធនាគារពិភពលោកបង្កើតនូវលក្ខខណ្ឌដែលនាំឱ្យមានការរីករាលដាលនៃHIV/AIDS ជាការកាត់បន្ថយថវិកាទៅលើសុខភាពដែលឈានទៅរកការកើនឡើងនូវជំងឺឱកាសនិយម ។ ជាញឹកញាប់ ល្បឿននៃការលុបបំបាត់ជាឯកតោភាគីនៃពន្ធ ការពារការអនុញ្ញាតឱ្យមានការនាំចូលម្ហូបអាហារដើម្បីផ្តល់រំលំកសិកម្មខ្នាតតូចក្នុងស្រុក នាំឱ្យមានការធ្វើនគូរូបនីយកម្ម ដោយសារបុរសចាកចោលគ្រួសារនិងភូមិរបស់ពួកគេដើម្បីស្វែងរកការងារធ្វើ ។ កំលាំងពលកម្មរបស់កម្មករ ចំណាកស្រុកបានបង្កើតឡើងគឺទំនងជានាំឱ្យពួកគេមានដៃគូរច្រើន ដែលបង្កើនឱ្យពួកគេមានការប្រថុយចំពោះការឆ្លងមេរោគហ៊ីវ ហើយក្រោយមកចំលងមេរោគនេះទៅដៃគូររបស់ពួកគេនៅក្នុងភូមិ ។

ប្រទេសហ្ស៊ីមបាវ៉េ គឺជាករណីមួយដែលចង្អុលបង្ហាញយ៉ាងច្បាស់ ។ តាំងពីការអនុវត្តិនៃ SAPsនៅទសវត្ស ៩០ ប្រទេសនេះមានបទពិសោធបញ្ច្រាសទិសនៃកំណើនក្នុងការថែរក្សាសុខភាពនៅកំឡុងពេលក្រោយការទទួលឯករាជ្យ ដោយសារការចំណាយត្រូវបានដកចេញពីខ្ទង់ចំណាយក្នុងសង្គម ។ យោងទៅតាមរដ្ឋមន្រ្តីសុខាភិបាលស៊ីមបាវ៉េ ការបែងចែកថវិកាសំរាប់ការថែរក្សាសុខភាពតាំងពីឆ្នាំ១៩៩០ បានធ្លាក់ចុះរវាង៣០-៣៧%ក្នុងប្រជាជនម្នាក់ ។ ការធ្វើឱ្យគាំងស្ទះប្រពន្ធ័ថែរក្សាសុខភាពក្នុងប្រទេសដទៃទៀត គឺការណែនាំនូវប្រពន្ធ័អតិថិជនត្រូវបង់ប្រាក់ ដែលធ្វើឱ្យចំនួននៃការធ្លាក់ចុះកាន់តែកើនឡើង ដែលត្រូវបានកត់សំគាល់លើការចំណាយលើការថែរក្សាសុខភាពក្នុងប្រជាជនម្នាក់ៗនៅគ្លីនិក ការទៅពិនិត្យសុខភាពនៅមន្ទីពេទ្យ សេវាមន្ទីរពិសោធន៍ វេជ្ជបញ្ជា និង សកម្មភាពផ្សេងៗទៀតដែលទាក់ទងនឹងសុខភាព ។ នៅក្នុងពេលជាមួយគ្នាអត្រានៃការឆ្លងមេរោគហ៊ីវ/ជំងឺអេដស៍នៅក្នុងប្រទេសស៊ីមបាវ៉េ បានកើនឡើងរហូតស្មើរតែ២៥%នៃមនុស្សពេញវ័យ ហើយនៅឆ្នាំ២០០០ ១.៧០០នាក់នៃប្រជាជនហ្ស៊ីមបាវ៉េស្លាប់ជារៀងរាល់សប្តាហ៍ដោយសារជំងឺផ្សេងៗដែលទាក់ទងនឹងមេរោគហ៊ីវ ដែលត្រូវបានប៉ាន់ស្មានថាជាអ្នកផ្ទុកមេរោគអេដស៍ ។ ជាមួយនឹង១/៤នៃអត្រាប្រជាជនហ្ស៊ីមបាវ៉េត្រូវបានប៉ាន់ប្រមាណនាពេលថ្មីៗថាមានផ្ទុកមេរោគហ៊ីវ ប្រពន្ធ័ថែរក្សាសុខភាព

ដែលមានកឹរិតទាបនោះបានអនុវត្តគម្រោង "ការថែទាំអ្នកជំងឺតាមផ្ទះ" ដែលបញ្ជូនអ្នកជំងឺអេដស៏ក្នុងស្ថាន-ភាពជំងឺចុងក្រោយបំផុត ទៅផ្ទះដើម្បីស្លាប់ ។ យោងទៅតាមបណ្ឌិតញូសុីមបាវ៉េលើបញ្ហាបំណុលនិងការអភិវឌ្ឍន៏ "នេះមានន័យថា សហគមន៏កំពុងតែរស់នៅក្នុងពិការភាពនៃភាពក្រីក្រត្រូវបានផ្តល់ឱ្យនូវបន្ទុកបន្ថែមទៀត ក្នុងការថែរក្សានូវជំងឺរបស់ពួកគេ" ។

## ការឃោសនា

# ៣

**"ធនាគារពិភពលោកគឺស្ថិតនៅក្នុងចំណោមអ្នកផ្តល់ជំនួយពីខាងក្រៅធំជាងគេបង្អស់សំរាប់កម្មវិធីសុខភាព**

ការផ្តល់ឱ្យប្រជាជនក្រីក្រនូវសុខភាពជាមូលដ្ឋាន និងចំណីអាហារគឺសំខាន់បំផុតសំរាប់ការកាត់បន្ថយភាពក្រីក្រនិងជំរុញឱ្យមានកំណើនសេដ្ឋកិច្ច ។ នៅខណៈពេលដែលកំណើនសំខាន់ៗបានរីកលូតលាស់នៅក្នុងប្រទេសជាច្រើនក្នុងកំឡុងពេលប៉ុន្មានទសវត្សមកនេះ ឧបសគ្គជាច្រើននៅតែមាន ។ ក្នុងចំណោមកុមារ១១លាននាក់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលនឹងស្លាប់រៀងរាល់ឆ្នាំ រវាង៧0%ស្លាប់ដោយសារជំងឺនៃការទំនាក់ទំនង (ដូចជារលាកសួត រាគ គ្រុនចាញ់ កញ្ជ្រិល និង HIV/AIDS) និងកង្វះចំណីអាហារ ។ ធនាគារពិភព-លោកបានសន្យាថា នឹងផ្តល់នូវប្រាក់កំចីថ្មីចំពោះកម្មវិធីសុខភាព អាហារូបត្ថម្ភ និង គំរោងនៃការអភិវឌ្ឍន៍ពិភពលោកផ្សេងទៀត ដែលគិតជាមធ្យមមានចំនួន១ពាន់លានដុល្លាក្នុងមួយឆ្នាំ។ ធនាគារក៏បានផ្តល់ជំនួយក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺគ្រុនចាញ់ទៅដល់៤៦ប្រទេស និង ៣0ប្រទេសទៀតចំពោះជំងឺរបេង។ នៅប្រទេសចិន ធនាគារបានជួយឧបត្ថម្ភអំបិលអ៊ីយ៉ូដច្រើនជាង៩0%នៃចំនួនគ្រួសារទាំងអស់ ដើម្បីកាត់បន្ថយចំពោះការរលូតកូនរបស់ស្ត្រី ការបង្កកំនើត ការប៉ះពាល់ផ្នែកសរីរាង្គរបស់កុមារ និងភាពចុះខ្សោយនៃគំនិតប្រាជ្ញារបស់ពួកគេជាដើម ដែលបណ្តាលមកពីកង្វះជាតិអ៊ីយ៉ូដនោះ ។ ធនាគារក៏បានជួយចំពោះកិច្ចគាំពារមាតា និងផ្តល់នូវអាហារូបត្ថម្ភដល់កុមារនៅក្នុងប្រទេសសេណេហ្កាល់ ព្រមទាំងជួយឧបត្ថម្ភដល់ការការពារក្នុងការធ្វើសមាហរណកម្ម ហើយនិងកិច្ចគាំពារកុមារនៅក្នុងប្រទេសប្រេស៊ីលផងដែរ។

## ការពិត

**ការផ្តល់ជំនួយភាគច្រើនរបស់ធនាគារពិភពលោកចំពោះកម្មវិធីសុខភាព គឺគេមានគំរោងទុកជាមុនរួចទៅហើយ គឺ "គេមិនបានគិតពីតំលៃនៃការបាត់បង់លើកំណែទំរង់រចនាសម្ព័ន និងនគរូបនីយកម្មឯកជនផ្សេងៗរបស់ប្រជាជនក្រីក្រនោះទេ" ។**

ចំនុចដទៃទៀតដែលអ្នកមិនដែលបានដឹងអំពីធនាគារពិភពលោកនោះ គឺគេមិនបានយកចិត្តទុកដាក់ក្នុងការប្រាប់ឈ្មោះមួយពិតប្រាកដចំពោះកម្មវិធី រឺ គំរោងនៃកម្មវិធីថែរក្សាសុខភាពណាមួយជាក់លាក់ឡើយ តែគេ

បែដាយកជំនួយទាំងនោះទៅប្រើប្រាស់នៅក្នុងការកែទំរង់ឡើងវិញនៅក្នុងផ្នែកណាមួយក្នុងការងារការិយាល័យ រឺ ក៏ធ្វើអាជីវកម្មរបស់វិនិយោគគិនឯកជននានាក្នុងវិស័យសុខភាពទៅវិញ។

កម្មវិធីនៃការគាំទ្រផ្នែកឥណទានក្នុងការកាត់បន្ថយភាពក្រីក្ររបស់ធនាគារពិភពលោក ត្រូវបានដាក់ឈ្មោះថ្មីមួយទៀតហៅថា កម្មវិធីនៃកំណែទំរង់រចនាសម្ព័ន្ធ ដោយប្រើវោហារសាស្ត្រដែលអាចផ្តល់ផលប្រយោជន៍ ហើយ "ទាញយកមកវិញនូវថ្លៃដែលជំពាក់ " ដោយបង្ខំអោយរដ្ឋាភិបាលខ្ចីប្រាក់ ក្រោយមកគេនឹងកាត់យកថវិការខ្លះៗ ពីសេវាកម្មសុខភាពសាធារណៈ។ កំឡុងឆ្នាំ១៩៨០ ការចំនាយទៅលើកម្មវិធីថែរក្សាសុខភាពបានស្រុតចុះចំនួន៥០%នៃប្រទេសក្រីក្រចំនួន៤២ ដែលជាប់ទាក់ទងនឹងធនាគារពិភពលោក ។ ក្នុងអំឡុងពេលសមាជសហរដ្ឋអាមេរិកបានសំនូមពរថា ប្រតិភូរតនាគាសហរដ្ឋអាមេរិកក្រោមការរៀបចំការបោះឆ្នោតជ្រើសរើសពហុភាគី ដើម្បីទប់ស្កាត់នូវរាល់បំណុលដែលរួមបញ្ចូលទាំងការដាក់កំរិតឱ្យធ្វើការបង់ពន្ធ ដែលមានលក្ខខណ្ឌត្រឹមត្រូវលើអ្នកដែលប្រើប្រាស់ថវិការក្នុងការសិក្សា ការថែទាំសុខភាពបឋម ហើយអាចឱ្យបុគ្គលិកផ្នែកសេដ្ឋសាស្ត្ររបស់ធនាគារបន្តប្រតិបត្តិ ដូចជាចំពោះអ្នកប្រើប្រាស់ថវិការជាដើម ដោយចុងក្រោយនេះសេវាកម្ម "សនិទាន" របស់គេនឹងធ្វើការសំរុះសំរួលដោយបង្ហាញឱ្យឃើញពីគំរូនៃ "គោលបំនងចំបង"របស់គេ ។ ភាពខុសគ្នានៃមុខងាររបស់វានិងតំលៃនៃការសិក្សាធនាគារពិភពលោក( បានបញ្ឈប់ការឧបត្ថម្ភថវិការក្នុងសេវាកម្មសុខភាព) ។ នៅពេលដែលធនាគារចង់បញ្ឈប់ការផ្តល់ថវិការយ៉ាងច្រើនក្នុងវិស័យនយោបាយ ធនាគារគ្រាន់តែលើកហេតុផលថា លក្ខខណ្ឌនៃសមាជកាន់តែមានភាពងាយស្រួលជាងមុនចំពោះអាណត្តិនៃថ្លៃជំពាក់មិនមានការប្រែប្រួលឡើយ ហើយធនាគារនឹងប្រកាសប្រាប់មន្ត្រីរាជការទាំងអស់(ដោយគ្មានការចុះកិច្ចសន្យាជាលាយលក្ខណ៍អក្សរអ្វីទាំងអស់)ថា ធនាគារមានសិទ្ធិក្នុងការដកលុយរបស់គេវិញក៏បានប្រសិនបើពួកគេមិនចង់បង្ខំឱ្យសាលាបិទទ្វាររឺបញ្ឈប់គ្រូបង្រៀននោះ ។ ធនាគារពិភពលោកធ្វើការទាមទារអ្នកដែលប្រើប្រាស់ថវិការថា អ្នកទាំងនោះត្រូវបានយកប្រាក់ទៅប្រើតែនៅពេលណាដែលជំងឺបានជាសះស្បើយហើយគេអាចមានលទ្ធភាព រឺមានគំនិតក្នុងការរកប្រាក់បង់ថ្លៃព្យាបាលរបស់ពួកគេបានប៉ុណ្ណោះ ប៉ុន្តែតាមការពិតពួកគេមិនបានយកចិត្តទុកដាក់លើការបង្កើនតំលៃនៃការថែរក្សាសុខភាពទេ ជាទូទៅគេប្រើថវិកាទាំងនោះលើចំនាយក្នុងគ្រួសារ ហើយយកលេសថាគេបានប្រើប្រាស់ថាវិការនោះក្នុងការស្រាវជ្រាវ និងជួយដល់ប្រជាជនក្រីក្រ ដែលប្រព្រឹត្តិទៅយ៉ាងល្អប្រសើរ។

ឧទាហរណ៍ដ៏អាក្រក់បំផុតនៃបញ្ហាដែលជាប់ពាក់ពន្ធ័នឹងការផ្តល់ជំនួយរបស់ធនាគារពិភពលោកចំពោះកម្មវិធីថែរក្សាសុខភាព គឺជាគំរោងមួយនៃការអភិវឌ្ឍប្រព័ន្ធសុខភាព (HSDP) នៅផាន់យ៉ាបប្រទេសឥណ្ឌាជាដើម។ លោកវិជ្ជបណ្ឌិត វីនីតា ហ្គូបតា ដែលជាវិជ្ជបណ្ឌិត និងជាលេខាធិការចាត់ការទូទៅប្រចាំនៅអ៊ិនសាហ្វ អន្តរជាតិបានរាយការណ៍អោយដឹងថា HSDP បាន"បង្កភាពច្របូកច្របល់ជាច្រើនក្នុងចំនោមអ្នកដែលគេឧបត្ថម្ភ និងអ្នកជំងឺក៏ដូចជាការកំនត់គោលដៅនៃការទទួលខុសត្រូវចំពោះសេវាកម្មនៃ ការផ្តល់អោយទោះបីជាចំពោះបុគ្គលិករបស់នាយកដ្ឋានសុខាភិបាលជាតិ និង សាជីវកម្មក៏ដោយ។ អ្នកប្រើប្រាស់ថវិការនៅតែមានការកើនឡើងដដែល ហើយការយកលេសថាជួយដល់អ្នកក្រីក្រនោះ គឺគ្មានប្រសិទ្ធិភាពអ្វីសោះដែលនៅទីនោះមានអ្នកជំងឺបដិសេដមិនព្រមទទួលយកនូវបញ្ហានេះចំនួនពី២០ទៅ៤០ភាគរយ។

ការផ្តល់ជំនួយដោយ HSDP បានប្រែក្លាយទៅជាការជួបជុំគ្នាផឹកតែ ហើយអនុវត្តន៏នូវអំពើពុករលួយមានន័យថា "ពួកគេទិញសឺរ៉ាំងដែលគ្មានថ្នាំសំរាប់ចាក់ ហើយទិញម៉ាសនិងមួកសំរាប់វះកាត់ផ្តល់អោយមជ្ឈមណ្ឌលដែលគ្មានប្រដាប់ប្រដារវះកាត់ទាល់តែសោះទៅវិញ"។ នៅពេលដែលគេប្រឈមមុខជាមួយសេចក្តីរាយការណ៏របស់កាសែតពីអំពើពុករលួយ និង ការគ្រប់គ្រងមិនបានល្អក្នុងការផ្តល់ជំនួយរបស់ធនាគារពិភពលោកដល់ ផាន់យ៉ាប អ្នកគ្រប់គ្រងសេដ្ឋសាស្ត្រផ្នែកសុខភាព និង អាហារូបត្ថម្ភ របស់ធនាគារពិភពលោកប្រចាំតំបន់អាស៊ីខាងត្បូង បានរៀបរាប់ពីអំពើពុករលួយថា វាគឺជា"បញ្ហាផ្ទៃក្នុង" របស់ ធនាគារដែលធនាគារ "មិនអាចធ្វើអន្តរាគមន៏បាន"។

គេយល់ថា អ្វីដែលគេត្រូវធ្វើដំបូងបង្អស់នោះគឺ ចូលរួមធ្វើការសំអាតទឹក ដើម្បីលើកស្ទួយដល់សុខភាពសាធារណៈ ធនាគារពិភពលោកបន្តជំរុញអោយមាននគរូបនីយកម្មឯកជន និង ដាក់សំពាធចំពោះរាជរដ្ឋាភិបាល ហើយធនាគារបានប្រកាសថា "បញ្ឈប់នូវរាល់គំនិតលើការយកថ្លៃទឹក"។ នេះគឺដើម្បីជំរុញអោយមានការកែប្រែសិទ្ធិមនុស្សជាមូលដ្ឋានថ្វីបើតំលៃមានកំរិតខ្ពស់ និង លទ្ធផលនៃនគរូបនីយកម្មឯកជនមានការតវ៉ាយ៉ាងធ្ងន់ធ្ងរនៅក្នុងប្រទេស បូលីវី ហ្កានញ៉ា និងប្រទេសដទៃ ទៀតក៏ដោយ។ នៅអាហ្វ្រិកខាងត្បូង ធនាគារពិភពលោកបានដឹកនាំនូវការចែកចាយការកែទំរង់ប្រព័ន្ធទឹកដែលបង្កអោយមានជំងឺអាសន្នរោគក៏ដូចជាការប្រើប្រាស់ប្រភពទឹកមិនស្អាតនៅតាមរមណីដ្ឋាននានានៃតំបន់ជនបទផងដែរ។

## ការឃោសនា

# ៤

### ធនាគារពិភពលោកគាំទ្រយ៉ាងខ្លាំងក្លាក្នុងការកាត់បន្ថយបំណុល

នៅក្នុងឆ្នាំ១៩៩៦ធនាគារពិភពលោកនិងមូលនិធិរូបិយវត្ថុអន្តរជាតិ(IMF) បានបើកយុទ្ធនាការនៃការផ្តួចផ្តើមសកម្មភាពរបស់ប្រទេសក្រីក្រដែលជំពាក់បំណុលយ៉ាងធ្ងន់ធ្ងរ(HIPC) យុទ្ធសាស្រ្តដ៏ទូលំទូលាយលើកតំបូងបំផុតដើម្បីកាត់បន្ថយបំណុលរបស់ប្រទេសក្រីក្របំផុតនៅលើពិភពលោក ជាពិសេសប្រទេសដែលជំពាក់បំណុលច្រើនជាងគេ ។ សព្វថ្ងៃនេះ មានប្រទេសចំនួន២៦ដែលបានទទួលគំរោងជួយកាត់បន្ថយបំណុលដែលមានចំនួនទឹកប្រាក់៤០ពាន់លានដុល្លាអាមេរិកចាប់តាំងពីពេលដែលគេចាប់ផ្តើមមក ។ ជាមួយនឹងទំរង់ផ្សេងៗនៃការកាត់បន្ថយបំណុល ការផ្តួចផ្តើមសកម្មភាពរបស់HIPC នឹងកាត់ចោល២/៣នៃបំណុលរបស់ប្រទេសទាំងនេះ បន្ថយបំណុលដែលជំពាក់ឱ្យមកនៅត្រឹមកំរិតមួយដែលនៅក្រោមកំរិតមួយរបស់ប្រទេសកំពុងអភិវឌ្ឍន៍ជារួម ។ ជាផ្នែកមួយនៃការផ្តួចផ្តើមសកម្មភាពនេះ ប្រទេសទាំងនេះធ្វើការស្វែងរកទិសដៅអាទិភាពនៃថវិការរបស់ពួកគេឆ្ពោះទៅរកគន្លឹះដើម្បីអភិវឌ្ឍន៍សង្គម និងធនធានមនុស្ស។ ឧទាហរណ៍ដូចជាប្រទេសរ៉្វាន់ដាជាដើម បានធ្វើគំរោងការបង្កើនការចុះឈ្មោះចូលរៀននៅបឋមសិក្សា និងជួលគ្រូបង្រៀន។ ប្រទេសបុនឌូរ៉ាស កំពុងតែមានគំរោងចែកចាយនូវការថែរក្សាសុខភាពជាមូលដ្ឋាន/សុខភាពមាតាយ៉ាងហោចណាស់អ្នកទទួលផលចំនួន១០០.០០០នាក់ នៅក្នុងសហគមន៍ក្រីក្រ ។ នៅប្រទេសកាមេរូនវិញ ធនធានជាច្រើនកំពុងតែត្រូវបានយកទៅប្រើប្រាស់ ដើម្បីពង្រឹងការប្រយុទ្ធប្រឆាំងហ៊ីវ/អេដស៍ ក្នុងចំណោមកម្មវិធីជាច្រើនទៀត ពង្រីកវិស័យអប់រំដើម្បីលើកកំពស់ការប្រើប្រាស់ស្រោមអនាម័យ ដោយក្រុមមនុស្សដែលប្រឈម មុខខ្លាំងក្លាចំពោះការឆ្លងជំងឺនេះ ។

## ការពិត

**ធនាគារពិភពលោកនៅតែបន្តទាញយកប្រាក់យ៉ាងច្រើនចេញពីលោកខាងត្បូង ជាជាងប្រាក់ដែលធនាគារដាក់ចូលទៅក្នុងតំបន់នេះ ។**

អំរែកនៃបំណុលក្រៅប្រទេសនៅតែជាបញ្ហាយ៉ាងធ្ងន់ធ្ងរសំរាប់ប្រទេសនានានៅលោកខាងត្បូង ។ ឧទាហរណ៍បំណុលដែលសន្មត់ផ្តល់ទៅអោយប្រទេសនានានៃអនុតំបន់សាហារ៉ានៅទ្វីបអាហ្វ្រិក មានចំនួនជាង៣៣០ពាន់

លានដុល្លា បីដងច្រើនជាងទឹកប្រាក់ដែលប្រទេសទាំងនេះទទួលបានពីការនាំផលិតផលចេញក្នុងមួយឆ្នាំៗ ។ គេបានប៉ាន់ប្រមាណថា ប្រាក់ចំនេញ២០%ដែលបានមកពីការនាំផលិតផលចេញរបស់ប្រទេសនានានៃអនុតំបន់សាហារ៉ានៅទ្វីបអាហ្វ្រិក លើកលែងតែអាហ្វ្រិកខាងត្បូងចេញត្រូវប្រើដើម្បីសងបំណុលដែលប្រទេសទាំងនេះជំពាក់បរទេស ។

ក្នុងមួយឆ្នាំៗ ធនាគារពិភពលោក ទទួលបានប្រាក់ពីការសងបំណុលរបស់ប្រទេសដែលក្រីក្របំផុតលើ ពិភព-លោកច្រើនជាងប្រាក់កម្ចីដែលផ្តល់ឱ្យប្រទេសទាំងនោះទៅទៀត សំរបសំរួលនូវដំណើរការផ្ទេរទ្រព្យសម្បត្តិយ៉ាងនឹងនរពីលោកខាងត្បូងទៅលោកខាងជើង ។ បំណុលនៅទ្វីបអាហ្វ្រិកបានកើនឡើង ៤០០ ភាគរយចាប់តាំងពីឆ្នាំ ១៩៨០មក។

ការផ្តួចផ្តើមសកម្មភាពរបស់ប្រទេសក្រីក្រដែលជំពាក់បំណុលយ៉ាងធ្ងន់ធ្ងរ (HIPC) ដែលបង្កើតឡើងដោយធនាគារពិភពលោក និង ស្ថាបន័្ទរូបិយវត្ថុអន្តរជាតិនៅឆ្នាំ១៩៩៦ គឺជាកំហុសជាមូលដ្ឋាននៃរចនាសម្ព័ន្ធរបស់វាហើយក៏ជាកំហុសនៅក្នុងការអនុវត្តផងដែរ ។ ការផ្តួចផ្តើមសកម្មភាពរបស់HIPC បានលើកលែងបំណុលតិចតួចបំផុតសំរាប់ប្រទេស ២-៣ ដែលមិនធ្វើឱ្យធនាគារពិភពលោក និង ស្ថាបន័្ទរូបិយវត្ថុអន្តរជាតិបាត់បង់ប្រាក់ចំណូលឡើយ ។ ដើម្បីទទួលបានផលចំនេញអប្បរមាពីកម្មវិធីHIPC រដ្ឋាភិបាលត្រូវតែធ្វើការបង្ហាញឱ្យឃើញមុននឹងយល់ព្រមជាមួយនឹងលក្ខខណ្ឌនៃកម្មវិធីកំណែទំរង់រចនាសម្ព័ន្ធរបស់IMF/ធនាគារពិភពលោក និងធ្វើការប្តេជ្ញាថា ក្នុងរយៈពេល ៣-៦-៩ រឺក៏២០ឆ្នាំទៅមុខទៀតនិងអនុវត្តកម្មវិធីកំណែទំរង់រចនាសម្ព័ន្ធនេះដែលជាកម្មវិធីយ៉ាងធ្ងន់ធ្ងរ ។

ធ្វើឱ្យអន្តរាយដល់បរិស្ថាន កិច្ចព្រមព្រៀងថ្នាក់ជាតិ និង បដិសេធលើសក្តានុពលនៃការកាត់បន្ថយភាពក្រីក្រនៃការលើកលែងបំណុល ។

កម្មវិធីHIPCមិនត្រឹមតែផ្តល់នូវការកាត់បន្ថយល្មមៗប៉ុណ្ណោះទេ ហើយសំរាប់កម្មវិធីខ្លះ ទោះជាយ៉ាងម៉េចក៏ដោយក៏គ្មានដែរ នឹងទុកឱ្យប្រទេសក្រីក្រទាំងនោះសងបំណុល ស្ទើរតែស្មើនឹងចំនួនដែលពួកគេកំពុងសងនៅពេលបច្ចុប្បន្ននេះ ។ នៅខណៈពេលដែលចំនួនទឹកប្រាក់នៃបំណុលពិតប្រាកដអាចនឹងធ្លាក់ចុះ មានប្រទេស

ប្រហែលជា១៥ប៉ុណ្ណោះដែលនឹងមើលឃើញថាចំនួនទឹកប្រាក់បំណុលដែលពួកគេសងនឹងធ្លាក់ចុះយ៉ាងគួរឱ្យកត់សំគាល់ ។ ការផ្តួចផ្តើមសកម្មភាពរបស់ HIPC ទទួលយកគោលការណ៍ ដែលនៅក្រោមការគិតឃើញរបស់វានោះគឺ "បំណុលដែលមានចិរភាព" ដែលវាចង្អុលបង្ហាញជាលក្ខណៈបំណុលដែលនឹងបាត់បង់បន្តិចម្តងៗលើសពី១៥០%នៃតំលៃនៃការនាំផលិតផលចេញប្រចាំឆ្នាំ ។ ក៏ប៉ុន្តែ ទោះបីជាមានការរំលោភលើមាត្រដ្ឋានដ៏ខ្ពស់នេះក៏ដោយ ធនាគារពិភពលោកសារភាពថា ពាក់កណ្តាលនៃបណ្តាប្រទេសដែលបានចុះឈ្មោះនៅក្នុងការផ្តួចផ្តើមសកម្មភាពរបស់HIPC នឹងមិនទទួលបានជោគជ័យនូវចិរភាពក្រោមកម្មវិធីនេះឡើយ ។ ប្រទេសយូហ្គានដា ជាប្រទេសទី១ដែលទទួលបានប្រយោជន៍ពីកម្មវិធីHIPC បង្ហាញឱ្យឃើញនូវការវិលត្រលប់ទៅក្នុងស្ថានភាព "មិនចិរភាព" មិនដល់ពីរឆ្នាំក្រោយមកផង ពីព្រោះតែប្រទេសនេះវាមានគំនិតសុទិដ្ឋិនិយមខ្លាំងពេកចំពោះការព្យាករណ៍របស់ស្ថាបន័រូបិយវត្ថុ អំពីថាតើប្រទេសនេះ អាចរកចំនូលបានប៉ុន្មាននៅក្នុងទីផ្សារកាហ្វេដែលមានដំនើរការរអាក់រអួលនោះ ។ ថ្វីបើប្រទេសនេះមានគុណសម្បត្តិគ្រប់គ្រាន់នៅក្នុងដំណាក់ទីពីរនៃការទាញយកប្រយោជន៍ក៏ដោយ ក៏វានៅតែមានផលវិបាកចំពោះស្ថានភាពមិនមានចិរភាពដដែល ។

វិបត្តិនៃបំណុល ដែលជាផ្នែកមួយដ៏ធំនៃលទ្ធផលរបស់ប្រាក់កម្ចីដ៏ច្រើនសន្ធឹកសន្ធាប់ដែលបានផ្តល់ទៅឱ្យរបបដែលពុករលួយនិងមិនមានលទ្ធិប្រជាធិបតេយ្យក្នុងអំលុងទសវត្សឆ្នាំ ៧០ និង៨០ រួមបញ្ចូលទាំងការផ្តល់ប្រាក់កម្ចីដែលដឹកនាំដែលផ្តោតលើផលចំណេញរបស់ធនាគារផ្សេងៗនៅលោកខាងជើង និងការគិតគូរលើសង្គ្រាមត្រជាក់ជាជាងក្តីកង្វល់អំពីការកាត់បន្ថយភាពក្រីក្រ ។ ភាគច្រើននៃប្រាក់កម្ចីទាំងនេះ មិនត្រូវបានប្រើឬក៏ធ្លាក់ទៅក្នុងហោប៉ៅរបស់ពួកអ្នកផ្តាច់ការហើយមិនដែលត្រូវបានប្រើសំរាប់ជាផលប្រយោជន៍របស់ប្រជាជនក្រីក្រ ដែលប្រជាជនទាំងនេះជាអ្នករ៉ាប់រងចំពោះការសងនូវប្រាក់កម្ចីទាំងនេះ ។

លទ្ធិដែលស្អប់ខ្ពើមបំណុល បានលើកឡើងយ៉ាងសាមញ្ញថាប្រទេសមួយ ជាពិសេសប្រជាជនរបស់ប្រទេសនោះមិនគួរត្រូវបានបង្ខំឱ្យសងបំណុលណាមួយដែលទទួលបានដោយគ្មានការពេញចិត្តពីពួកគេ និងប្រឆាំងទៅនឹងផលប្រយោជន៍របស់ពួកគេ ។ លទ្ធិ ដែលត្រូវបានប្រើនៅចុងសតវត្សទី១៩ដោយសហរដ្ឋអាមេរិក លើការទទួលយកប្រទេសគុយបាមកធ្វើជាប្រទេសក្រោមអាណានិគមរបស់ខ្លួន ក្រោយសង្គ្រាមរវាងអាមេរិកនិងអេស្ប៉ាញ ត្រូវបានប្រើយ៉ាងម៉ត់ចត់នៅក្នុងប្រវត្តិសាស្ត្រ ។ អ្វីដែលគួរឱ្យចាប់អារម្មណ៍ជាងនេះទៅទៀតនោះ

គឺថា បច្ចុប្បន្ននេះលទ្ធិនោះកំពុងតែមានជីវិតរស់សារជាថ្មីម្តងទៀត ទោះបីជាមិនមែនដោយឈ្មោះ តែដោយសាររដ្ឋការរបស់ Bush ដែលកំពុងតែដាក់គំនាបចំពោះការលុយចោលបំណុលរបស់ប្រទេសអ៊ីរ៉ាក់ដែលបំណុលនេះកើតឡើងនៅក្នុងរបបBa'athist ។ ការលាក់ពុតដែលគ្មានភាពអៀនខ្មាសនៃកលល្បិចនយោបាយនេះ ធ្វើការពន្យល់យ៉ាងតិចតួចបំផុតថា ហេតុអ្វីបានជាអំពាវនាវឱ្យមានការលុបចោលបំណុលដែលគួរឱ្យស្អប់ខ្ពើមនៅប្រទេសអាហ្វ្រិខាងត្បូង នីការ៉ាហ្គ័រ វី សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ដែលប្រទេសទាំងអស់នោះសុទ្ធតែទទួលរងការឈឺចាប់ នៅក្រោមរដ្ឋាភិបាលដែលបង្ហាញយ៉ាងច្បាស់ នូវការគាបសង្កត់និងភាពគ្មានលទ្ធិប្រជាធិបតេយ្យ ហើយដំណើរការទៅដោយគ្មានការយកចិត្តទុកដាក់សោះ ។

ធនាគារពិភពលោកធ្វើការតវ៉ាដដែលៗថា បើសិនជាលើកលែងបំណុលរបស់ប្រទេសមួយចំនួន នឹងធ្វើឱ្យខូចខាតផលប្រយោជន៏របស់ប្រទេសដទៃទៀតក្នុងការដឹកនាំរបស់គេ ។ មិនត្រឹមតែថារឿងនេះអាចជាការពិភាក្សាយ៉ាងម៉ត់ចត់បានឬអត់នោះទេអំពីរឿងការឱ្យប្រាក់ខ្ចី ជាមួយនឹងលក្ខខណ័ដែលតឹងរឹងនិងធ្វើឱ្យវិនាសដែលតែងតែភ្ជាប់មកជាមួយគឺធ្វើឱ្យមានផលល្អជាជាងការធ្វើឱ្យវិនាស ប៉ុន្តែការតវ៉ារបស់វា គឺជាការក្លែងបន្លំ ។ របាយការផ្សេងគ្នាពីរដែលបានបញ្ចប់នៅរដូវផ្ការីកឆ្នាំ២០០១ គណនេយ្យករឯករាជ្យម្នាក់ឈ្មោះថា Subhrendu Chatterji និង គណនេយ្យករជាច្រើនរូបទៀតនៅក្រុមហ៊ុន Chantrey Vellacott បានសន្និដ្ឋានថា "ធនាគារពិភពលោក និងស្ថាបន័រូបិយវត្ថុអន្តរជាតិ អាចនឹងមានលទ្ធភាពក្នុងការលុបចោល១០០%នូវបំណុលដែលជំពាក់ស្ថាបន័ទាំងពីរនេះ ដោយប្រទេសក្រីក្រដែលជំពាក់បំណុលយ៉ាងធ្ងន់ធ្ងរHIPC ដោយគ្មានភាពអន្តរាយអ្វីដល់សមត្ថភាពរបស់ស្ថាបន័ទាំងនេះ ក្នុងការបំពេញនូវមុខនាទីរួមរបស់ពួកគេ "។ ការសិក្សាប្រហាក់ប្រហែលគ្នាមួយដែលដឹកនាំដោយ បណ្តាញបំណុលនិងការអភិវឌ្ឍន៏របស់ប្រទេសអៀរឡង់ ដែលបានបញ្ចប់នៅខែកញ្ញា ឆ្នាំ២០០៣ បានរកឃើញនូវការសន្និដ្ឋានដូចគ្នា មិនត្រឹមតែជាការអះអាងរបស់ធនាគារពិភពលោកដែលថា ពួកគេមិនអាចលុបចោល១០០%នូវបំណុលដែលក្លែងបន្លំនោះទេ ប៉ុន្តែធនាគារមានធនធាន យ៉ាងច្រើនសន្ធឹកសន្ធាប់ សំរាប់ធ្វើការលុបចោលបំណុលដោយគ្មានភាពអន្តរាយដល់ឥណទាន ប្រចាំថ្ងៃឬប្រតិបត្តិការរបស់ធនាគារឡើយ ។

## ការឃោសនា

៩ "ធនាគារពិភពលោកគឺជាអ្នកផ្តល់ជំនួយអន្តរជាតិដ៏ធំមួយលើគំរោងជីវសាស្ត្រចំរុះ ។

តាំងពីឆ្នាំ ១៩៨៨ ធនាគារបានក្លាយជាអ្នកផ្តល់ជំនួយអន្តរជាតិដ៏ធំមួយលើគំរោងជីវសាស្ត្រចំរុះ ។ ទោះបីជាការបាត់បង់ជីវសាស្ត្រចំរុះគឺជាក្តីកង្វល់របស់ពិភពលោកទាំងមូលក៏ដោយ តំលៃនៃការបាត់បង់ដ៏ធំសម្បើមគឺជាការចាប់អារម្មណ៍របស់ប្រជាជនដែលរស់នៅទីជនបទនៅប្រទេសកំពុងអភិវឌ្ឍន៍ ប្រជាជនភាគច្រើនដែលពឹងផ្អែកយ៉ាងខ្លាំងទៅលើបរិស្ថានសំរាប់អាហារ ជំរក ថ្នាំព្យាបាល ចំណូល ការងារនិងអត្តសញ្ញាណវប្បធម៌របស់ពួកគេ ។ សំរាប់ហេតុផលនេះ ធនាគារបានចូលរួមជាមួយអភិរក្សអន្តរជាតិ សម្បទានបរិស្ថានពិភពលោក មូលនិធិ MacAthur និងរដ្ឋាភិបាលជប៉ុននៅក្នុងការចាប់ផ្តើមជំនួយដែលនឹងធ្វើការឧបត្ថម្ភលើការការពារឱ្យបានកាន់តែប្រសើរឡើងនូវជីវសាស្ត្រចំរុះនៅតំបន់ក្តៅផ្សេងៗនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ៦០% នៃពូជ ជីវសាស្ត្រចំរុះនៅលើពិភពលោកអាចរកឃើញនៅក្នុងតំបន់ដែលរងនូវការគំរាមកំហែងទាំងនេះ ដែលគ្របដណ្តប់លើផ្ទៃ១.៤% នៃសំបកផែនដីទាំងមូល ។ ក្តីកង្វល់ចំពោះបរិស្ថានគឺជាផ្នែកដ៏សំខាន់នៃបេសកម្មកាត់បន្ថយភាពក្រីក្ររបស់ធនាគារពិភពលោក ។ បន្ថែមពីលើគោលនយោបាយនៃការប៉ាន់ស្មាននិងការថែរក្សាបរិស្ថាន យុទសាស្ត្រថ្មីលើបរិស្ថានគឺផ្តោតទៅលើការផ្លាស់ប្តូរធាតុអាកាស ព្រៃឈើ ធនធានទឹកនិង ជីវ-សាស្ត្រចំរុះ ។ ថ្មីៗនេះ តំណែងថ្មីនៃគំរោងផ្សេងៗជាមួយនឹងគោលបំណងជាក់លាក់លើបរិស្ថានគឺមានទឹកប្រាក់ប្រមាណ ១៣ពាន់លានដុល្លា ។"

## ការពិត

**"ធនាគារពិភពលោកផ្តល់ប្រាក់ជំនួយសំរាប់គំរោងដែលបន្តបំផ្លិចបំផ្លាញបរិស្ថានយ៉ាងសម្បើមដោយមិនថយក្រោយឡើយ ។**

ការប៉ុនប៉ងរបស់ធនាគារពិភពលោកដើម្បីប្តូរពណ៌ខ្លួនរបស់វាឱ្យទៅជា កេរ្តិ៍ឈ្មោះ "បៃតង " គឺមិនលុបចោលនូវមូលដ្ឋានគ្រឹះនៃការវិនិយោគយ៉ាងច្រើនសន្ធឹកសន្ធាប់របស់ខ្លួនលើអណ្តូងប្រេងកាត ធនធានរ៉ែ ឧស្ម័ន និងគំរោងទំនប់ដែលបំផ្លិចបំផ្លាញបរិស្ថាន និងសង្គម ដោយមិនគិតអំពីប្រាក់កម្ចីឬជំនួយឥតសំណងតិចតួចដើម្បី

គាំទ្រជីវសាស្ត្រចំរុះឡើយ ។ គំរោងប្រពន្ធ័គមនាគមន៍ទាំងនេះនាំទៅរកការខូចខាតបរិស្ថានដែលជាមហន្ត-រាយចំពោះសហគមន៏ក្នុងមូលដ្ឋាន ហើយកំរនឹងនាំមកនូវការងារដែលមានរយៈពេលយូរ ឬក៏លើកកំពស់ក៏រិតជីវភាពរស់នៅរបស់ប្រជាជន ។ ការវិនិយោគរបស់ធនាគារពិភពលោកជាពិសេសលើរ៉ែប្រេងធ្វើឱ្យអន្តរាយចំពោះឥទ្ធិពលវិជ្ជមានដែលកម្មវិធីបរិស្ថានរបស់ធនាគារអាចផ្តល់ឱ្យ ។ ច្បាស់លាស់ជាងនេះទៅទៀតនោះគឺបំពង់បង្ហូរប្រេងនិងឧស្ម័នរបស់ធនាគារពិភពលោក ទំនប់និងគំរោងផ្សេងៗដែលជាដំណើរការឆ្លងកាត់ ឬក៏ទឹកជំនន់លំនៅដ្ឋានដែលគំរោងជីវសាស្ត្រចំរុះរបស់ធនាគារពិភពលោកមានគោលបំណងធ្វើឱ្យសំរេច ។ នៅប្រទេសកាមេរូន ធនាគារពិភពលោកយកឥណទានចំនួន ៣៦លានដុល្លាសំរាប់គំរោងអភិរក្សនិងគ្រប់គ្រងជីវសាស្ត្រចំរុះដើម្បី "បង្រួបបង្រួមនិងលើកកំពស់ការគ្រប់គ្រងនៃតំបន់ក្នុងគំរោង" ក៏ប៉ុន្តែបានធ្វើតាមដោយដឹកនាំលុយរាប់រយលានដុល្លាយកទៅឧបត្ថម្ភបំពង់បង្ហូរប្រេងChad-កាមេរូន ដែលហូរកាត់និងបំពុលតំបន់ព្រៃឈើដែលសំបូរភ្លៀងនៅកាមេរូន ។

រវាងឆ្នាំ ១៩៩២និងឆ្នាំ ២00៣ ធនាគារពិភពលោកបានផ្តល់ប្រាក់ខ្ចីចំនួន២៦.៥ពាន់លានដុល្លាដល់គំរោងរ៉ែប្រេងដែលគំរោងនេះជាយថាហេតុបានបញ្ចេញឧស្ម័កាបូនិចចំនួន៤៨ពាន់លានតោន ហើយក៏ជាមូលហេតុចំបងនៃការឡើងកំដៅរបស់ពិភពលោកទៅក្នុងបរិយាកាសផងដែរ ។ ធនាគារពិភពលោកទទួលស្គាល់នូវការពិតនៃការផ្លាស់ប្តូរ អាកាសធាតុ ហើយនឹងការរងទុក្ខវេទនាដោយសារតែការកើតមានឡើងនូវការខូចខាតដំនាំ គ្រោះទឹកជំនន់ និងអាកាសធាតុដ៏ខ្លាំងក្លាចំពោះប្រជាជននៅក្នុងប្រទេសក្រីក្រ (ក៏ដូចជាផលប៉ះពាល់នៃការឡើងកំដៅនៅក្នុងពិភពលោកចំពោះជីវសាស្ត្រចំរុះ) ។ តែធនាគារពិភពលោកបដិសេធក្នុងការទទួលស្គាល់ថា វាគឺជាពិរុទ្ធកជនយ៉ាងធំមួយដែលនាំយករ៉ែប្រេង ឬក៏ធ្វើការផ្លាស់ប្តូរអាទិភាពក្នុងការឱ្យប្រាក់កម្ចីរបស់វា ។

គ្រប់សន្លឹកប្រាក់ ១ដុល្លាដែលបានធ្វើវិនិយោគនៅក្នុងភាពស្អាតនិងចិរភាពនៃប្រភពថាមពល ១៨ដុល្លាគឺត្រូវបានចំណាយទៅលើការអភិវឌ្ឍន៏រ៉ែប្រេង ។ ជំនួសឱ្យការពន្លឿនការអភិវឌ្ឍន៏និងអនុវត្តន៏បច្ចេកវិជ្ជាថាមពលដែលស្អាត និងអាចប្រើប្រាស់បានជាថ្មី ដែលអាចផ្តល់ភ្លើងដល់សហគមន៏ក្រីក្រដោយផ្ទាល់ជាជាងការនាំចូលប្រេងឥន្ធនៈ ធនាគារពិភពលោកកំពុងតែបញ្ជូនប្រទេសកំពុងអភិវឌ្ឍន៏ឱ្យធ្លាក់ចុះទៅក្នុងផ្លូវដូចគ្នានឹងការពឹងផ្អែកលើរ៉ែប្រេងដែលបច្ចុប្បន្ននេះកំពុងតែរំខានប្រទេសដែលអភិវឌ្ឍន៏ ។

ហើយភាពមិនទទួលខុសត្រូវរបស់ធនាគារពិភពលោកគឺបានពង្រីកបន្តដល់វិស័យគ្រប់គ្រងសំណល់ផងដែរ ។ លើសពីភស្តុតាងដែលពេញបរិបូណ៌ដែលថា ការដុតសំណល់ឱ្យក្លាយទៅជាផេះ គឺជា "វិធីសាស្ត្រដែលគ្រោះថ្នាក់ហើយចំណាយថវិកាច្រើន និងមិនមានចិរភាពសំរាប់ការគ្រប់គ្រងសំណល់ "ធនាគារពិភពលោកបានគ្រោងនូវការដុតសំណល់ឱ្យក្លាយទៅជាផេះ ចំនួន២៦លើកថ្មីទៀតតាំងពីឆ្នាំ២០០១ ។ ក្រុមអ្នករិះគន់បានលើកឡើងថា ការដុតសំណល់ឱ្យក្លាយទៅជាផេះគឺជាប្រភពចំបងនៃឌីអុកស៊ីតនៅក្នុងពិភពលោក ដែលត្រូវបានបង្ហាញឱ្យឃើញថា ជាមូលហេតុដែលបណ្តាលឱ្យមានការកើតជំងឺមហារីកយ៉ាងច្រើនការខូចប្រព័ន្ធការពាររាង្គកាយបញ្ហាប្រព័ន្ធបន្តពូជនិងការវិវត្តន៏ជាដើម ។

## ការឃោសនា

# ៦ “ធនាគារពិភពលោកធ្វើការជាមួយដៃគូច្រើនជាងមុន.

កំឡុងពេល៦ឆ្នាំកន្លងមក ធនាគារបានចូលរួមក្នុងលំដាប់ជួរមុខនៃដៃគូជាច្រើនលើពិភពលោកដែលប្រឆាំងនិងភាពក្រីក្រ ។ ឧទាហរណ៏ដូចជាក្នុងកិច្ចខិតខំប្រឹងប្រែងជួយកាត់បន្ថយនូវផលប៉ះពាល់នៃការឡើងកំដៅនៅលើផែនដី ធនាគារបានសហការជាមួយរដ្ឋាភិបាលនិងស្ថាប័នឯកជន ដើម្បីបើកយុទ្ធនាការមូលនិធិជីវសាស្ត្រកាបូន(BioCarbon Fund)ថ្មី ហើយជាមួយនិងសមាគមផ្សព្វផ្សាយពាណិជ្ជកម្មអន្តរជាតិ(IETA) ដើម្បីបើកយុទ្ធនាការ មូលនិធិអភិវឌ្ឍន៏កាបូននៅសហគមន៏(CDCF) ។ ធនាគារក៏កំពុងធ្វើការជាមួយមូលនិធិជីវិតសត្វព្រៃពិភពលោកដើម្បីការពារព្រៃឈើផងដែរ ។ ជាមួយនិងអង្គការកសិកម្មនិងស្បៀងអាហារពិភពលោក (FAO) និងកម្មវិធីអភិវឌ្ឍន៏របស់អង្គការសហប្រជាជាតិ(UNDP) ធនាគារធ្វើការឧបត្ថម្ភ/ជួល ក្រុមប្រឹក្សាពិគ្រោះយោបល់លើការស្រាវជ្រាវកសិកម្មអន្តរជាតិ-ដែលដឹកនាំចលនាវិទ្យាសាស្ត្រដ៏ទំនើបបំផុត ដើម្បីកាត់បន្ថយការស្រេកឃ្លាននិងភាពក្រីក្រ លើកកំពស់ចំណើនិងសុខភាពរបស់មនុស្សជាតិនិងការពារបរិស្ថាន ។ តាមរយៈក្រុមផ្តល់យោបល់ដើម្បីជួយដល់អ្នកក្រីក្រ ធនាគារធ្វើការជាមួយ២៧ពហុ-ភាគី និងអង្គការម្ចាស់ជំនួយដែលគាំទ្រហិរញ្ញទានខ្នាតតូច ដើម្បីជួយកសាងប្រព័ន្ធហិរញ្ញទានដែលមានគុណភាពនិងសេវាខ្ពស់នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៏ ដើម្បីបំរើប្រជាជនដែលក្រីក្របំផុតក្នុងប្រទេសនោះ ។ ភាពជាដៃគូដើម្បីទទួលជោគជយ័ទាំងស្រុងក្នុងការកំចាត់ប៉ារ៉ាស៊ីតដែលរស់នៅក្នុងទឹកដែលបណ្តាលឱ្យមានជំងឺងងឹតភ្នែកនៅទូទាំងតំបន់អាហ្វ្រិកដែលទទួលបានជោគជ័យក្នុងការបង្ការបានចំនួន ៧00000ករណើងងឹតភ្នែក ដីទំហំ២៥លានហិចតាដែលអាចប្រើប្រាស់បានដើម្បីធ្វើកសិកម្ម ហើយព្យាបាលប្រជាជន ៣៥លាននាក់ពីជំងឺនេះក្នុងមួយឆ្នាំៗ ។

## ការពិត

## ការចូលរួម និង ឥទ្ធិពលរបស់ធនាគារពិភពលោកនៅក្រោមភាពជាដៃគូគឺមានលក្ខណៈអាក្រក់ជាងមុន

ដៃគូមួយនៃធនាគារពិភពលោកអួតអាង ហើយជារឿយៗវាតែងតែធ្វើការគ្រប់គ្រងហើយ មានទំនាក់ទំនងយ៉ាងកក់ក្តៅជាមួយសាជីវកម្មធំៗបំផុតលើពិភពលោកដែលមិនអើពើនិងបញ្ហាផ្សេងៗ ។ គោលនយោបាយរបស់ធនាគារលើដៃគូក្នុងវិស័យឯកជនតំរូវឱ្យសាជីវកម្មធំៗ ដែលចូលរួមធ្វើការពិនិត្យពិច្ច័យយ៉ាងជិតស្និតក្នុងភាពជាដៃគូរ។ ហើយពួកគេធ្វើការគិតគូស្រុះស្រួលគ្នាជាមួយជនគោលដៅរបស់ធនាគា កន្លែងណាក៏ដោយដែលទាក់ទង ។ ធនាគារអះអាងថា វាគឺជាការប៉ាន់ស្មានអំពីកេត្តនាមរបស់ក្រុមហ៊ុនជាមួយនិងភ្នែករបស់ពួកគេ ការទទួលខុសត្រូវលើបញ្ហាផ្សេងៗរបស់សង្គមសាជីវកម្មទោះជាដៃគូតំណាងអោយជំលោះនៃផលប្រយោជន៍ក៏ដោយ ។ ឧទាហរណ៍ ទោះជាក្រុមហ៊ុនកំពុងតែស្វែងរកកេរ្តិ៍ឈ្មោះ កិច្ចសន្យារបស់កម្មវិធីធនាគារវិមូនិធិ ទោះជាយ៉ាងណាក៏ដោយ ការចូលក្នុងភាពជាដៃគូរបស់ធនាគារជាមួយនិងវិស័យ ឯកជនជាពិសេសផលប្រយោជន៍ពីក្រុមហ៊ុនជាដៃគូទទួលបានរឺផ្តល់ឱ្យនូវពត៌មានទីផ្សារដែលមានប្រយោជន៍ផ្សេងៗ ។ អ្វីដែលស្ថិតនៅក្នុងលក្ខខណ្ឌ័ឈានមុខក្នុងភាពជាដៃគូ គឺនៅក្នុងជួរជាមួយនិងគោលនយោបាយរឺយុទ្ធសាស្រ្តធនាគារ ។ ជាមួយនិងគោលនយោបាយជាច្រើនរបស់ធនាគារវាអនុវត្តន៏អោយមាននូវការតស៊ូទៅតាមពាក្យបណ្តឹង។

ជាការពិតណាស់ ធនាគារបានចូលជាដៃគូជាមួយសាជីវកម្មធំៗដែលអាក្រក់ក្រោមកម្មវិធី ផ្លាស់ប្តូរបុគ្គលិកបានចាប់ផ្តើមធ្វើនៅក្នុងឆ្នាំ ១៩៩៥ ដោយប្រធានធនាគា ជាម វូលហ្វិនស៊ុន កម្មវិធីផ្លាស់ប្តូរបុគ្គលិកគឺបានអនុញ្ញាតិឱ្យបុគ្គលិកធនាគារសុំព្យួរការងារពីធនាគារទៅធ្វើការអោយសាជីវកម្មគ្រប់ប្រភេទ ។ មានចំនួន៨៥ ដៃគូ ដែលបានចូលរួមនៅក្នុងកម្មវិធីនេះហើយដែលគ្រប់គ្រងដោយពហុគោភាគីនិយម ។ គុណប្រយោជន៍របស់ធនាគារពិភពលោកភាគច្រើនគឺជាកិច្ចសន្យា រឺជាការធានារ៉ាប់រងរបស់ធនាគារចំពោះអតិថិជន។ ធនាគារល្បីៗ ដូចជា Citibank, Exxon-Mobil និង Shell ។ ក្រសួងឃោសនាការ អះអាងដែរថារឿងជំរំជំរះសាជីវកម្ម គឺជាផ្នែកមួយនៃដំណោះស្រាយ ប្រតិបត្តិការរយៈពេលវែងជាមួយនិងធនាគារធើបផុតពីភាពក្រីក្រនៅលើពិភពលោក ប៉ុន្តែរាល់ការលើកទឹកចិត្តរបស់ពួកគេគឺផ្ទុយពីការពិត ខណៈពេលនៃការបដិសេធន៍នូវការផ្លាស់ប្តូរបង្កើតអោយមាននូវជំលោះនៃអត្ថប្រយោជន៍Pauline Ramprasad របស់ធនាគារហើយធ្វើការទទួលយល់ព្រមដែលសាជីវកម្មមានទំនាក់ទំនងជាមួយនិងគោលនយោបាយប្រទេស ផ្តល់ផល

ប្រយោជន៏ នៅពេលឱកាសមកដល់ដើម្បីធ្វើការដេញថ្លៃលើកិច្ចសន្យាធនាគារ ។ Aventis, Syngenta and Dow Agrosciences, all agro-industrial giants, គឺមានក្រុមហ៊ុនមួយចំនួនដែលជាដៃគូរបស់ធនាគារ បានប្រើប្រាស់នូវកម្មវិធីផ្លាស់ប្តូរបុគ្គលិកនេះ ។

ក្រុមហ៊ុនឯកជនភាគច្រើនរួមគ្នាជាមួយធនាគារបានលើកឡើងនៅភាពមិនគ្រប់គ្រាន់នៃ ទង់ជាតិក្រហម ។ ក្រុមហ៊ុនផលិតថ្នាំសំលាប់សត្វល្អិតចំនួនបីយោងទៅតាមហាងលើឧទាហរណ៍ ដែលមានប្រវត្តិក្នុងការ ដាក់ជាផលប្រយោជន៏មុននិងដាក់ជាសាធារណៈ យោងទៅតាមបណ្តាញការងាររបស់ផលិតផលថ្នាំសំលាប់សត្វ ល្អិត រួមមានដូចជា ការដឹកជញ្ជូនថ្នាំពុលខុសច្បាប់ ភាពគ្រោះថ្នាក់នៃកន្លែងចោលជាតិគីមី Superfund sites ការធ្វើតេសជាតិគីមីទៅលើមនុស្ស ការផ្សព្វផ្សាយធ្លាក់ចុះ និង ការផ្តន្ទាទោសអ្នករកស៊ីទុច្ចរិត ។ ជាងនេះទៅទៀតក្រុមហ៊ុនទាំងនេះមានប្រវត្តិជាក្រុមហ៊ុនដែលគ្មានក្រមសិលធមិ ការសំរេចចិត្តចុះឈ្មោះថ្នាំសំលាប់សត្វល្អិតក្លែងក្លាយ ភាពពុករលួយ ការបដិសេធការដកផលិតផលចេញដែលបានដឹងពីហេតុផលជាញឹកញាប់ពីការរបួសនិងស្លាប់នៃការប្រើលុយសំរាប់បង្ហាញនូវពត៌មានជាសាធារណប៉ុន្តែពត៌មានទាំងនោះ គឺមិនពិតអំពីគ្រោះថ្នាក់ទៅលើសុខភាពនិង បរិយាកាសនៃផលិតផលទាំងនោះទេ ។ ទោះជាពេលកង្វល់នៃការកើតឡើងដោយធនធានឯករាជ្យក៏ដោយ ។

## ការឃោសនា

# ៧ ធនាគារពិភពលោកគឺជាអ្នកដឹកនាំក្នុងការប្រឆាំងទៅនិងអំពើពុករលួយនៅទូទាំងពិភពលោក

អំពើពុករលួយ គឺជាការរាំងស្ទះទៅនឹងការអភិវឌ្ឍន៍ ។ ធនាគារពិភពលោកបានយកពន្ធពីប្រជាជនដែលក្រីក្រដោយធ្វើការផ្លាស់ប្តូរពីធនធានសាធារណៈដែលប្រជាជនត្រូវការបំផុត ។ ធនាគារក៏បានធ្វើឱ្យអន្តរាយដល់ការវិនិយោគទុន ធនធានមនុស្ស ការរីកចំរើន សំលេង និងសមភាពផងដែរ ។ តាំងពីឆ្នាំ ១៩៩៦ ធនាគារបានបើកយុទ្ធនាការកម្មវិធីអភិបាលកិច្ច និងកម្មវិធីប្រឆាំងទៅនិងអំពើពុករលួយជាច្រើន និងការចាប់ផ្តើមសកម្មភាព អភិបាលកិច្ចនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ច្រើនជាង១០០ ។ ការផ្តួចផ្តើមសកម្មភាពមានតាំងពីការផ្សព្វផ្សាយជាច្រើន ពីទ្រព្យសម្បត្តិដោយមន្ត្រីសាធារណៈរហូតដល់ការបណ្តុះបណ្តាលចៅក្រម និងការបង្រៀនពីរបៀបស៊ើបអង្កេតនិងរាយការណ៍ដល់អ្នកកាសែត ។ ការប្តេជ្ញារបស់ធនាគារក្នុងការដោះស្រាយអំពើពុករលួយបានជួយចំលើគោលដៅចំពោះការឆ្លើយតបជាសកលអំពីបញ្ហានេះ នៅខណៈពេលដែលធនាគារបន្ត ការដាក់បញ្ចូលវិធានការប្រឆាំងនិងអំពើពុលរលួយ ទៅក្នុងការងារវិភាគនិងអនុវត្តរបស់ធនាគារ ។ ធនាគារ កំពុងតែប្តេជ្ញានិងធានាថា កម្មវិធីដែលឧបត្ថម្ភដោយធនាគារពិភពលោកមិនទាក់ទងនឹងអំពើពុករលួយ ហើយបានធ្វើការរៀបចំនូវការណែនាំដ៏តឹងរឹង និងបណ្តាញទូរសព្ទ២៤ម៉ោង សំរាប់ការប្តឹងអំពីបញ្ហាអំពើពុករលួយ មានអង្គការជាង១០០ដែលត្រូវបានប្រកាសថាមិនមានគុណសម្បត្តិដើម្បីទទួលបានជំនួយផ្នែកថវិកាជាមួយនិងកុងត្រារបស់ធនាគារឡើយ ។ ជាងនេះទៅទៀត ស្ថាប័នធនាគារពិភពលោកបានធ្វើការអភិវឌ្ឍន៍នូវចំណេះដឹងសំខាន់ៗ ការសិក្សានិងមជ្ឈមណ្ឌលទិន្នន័យលើអភិបាលកិច្ច និងការប្រឆាំងអំពើពុករលួយ ។

## ការពិត

**ធនាគារពិភពលោកនៅតែជាដៃគូរមិនល្អ ក្នុងជំហ៊ាននៃអំពើពុករលួយ ។**

ក្នុងអត្ថបទដែលបានដាក់ជូនសិទ្ធិសិតពិភពលោកនៅឆ្នាំ១៩៩៣ ស្តីពីសិទ្ធិមនុស្ស ធនាគាពិភពលោកលើកឡើងដូចតទៅ: " ធនាគារពិភពលោកមិនគិតគូរពីការវាស់វែងផ្នែកនយោបាយនៃសិទ្ធិមនុស្សនៅក្នុងកិច្ចព្រម

ព្រៀងលើប្រាក់កម្ចីរបស់ធនាគារទេ ។ ក្នុងមាត្រនៃកិច្ចព្រមព្រៀងគឺហាមឃាត់ដល់ស្ថាប័ននានា ពីការពិចារណាលើបញ្ហានយោបាយ ជ្រៀតជ្រែកក្នុងកិច្ចការនយោបាយរបស់ប្រទេសណាមួយ រឺក៏ប៉ះពាល់ដោយសារការណែនាំពីទំរង់នយោបាយរបស់ប្រទេសណាមួយឡើយ ។

ឯកសារទំនាក់ទំនងដែលបានបោះពុម្ពផ្សាយនាពេលថ្មីៗនេះ ដោយនាយកដ្ឋានទំនាក់ទំនងខាងក្រៅអន្តរជាតិបានលើកឡើងថាប្រជាធិបតេយ្យគឺជាឧបសគ្គសំរាប់ឯកជនភាវូបនីយកម្ម ។ ឯកសារនោះមិនដែលសំណូមពរថាធនាគារពិភពលោកឬក៏រដ្ឋាភិបាលនៃប្រទេសមួយគួរតែប៉ាន់ប្រមាណនូវភាពសមរម្យនៃការជជែកដែលលើកឡើងដោយប្រជាជនដើម្បីប្រឆាំងទៅនឹងគោលនយោបាយរបស់ធនាគារ តែធនាគារបែជាច្រានចោលនូវការជជែកបែបនេះដែលជាការឃោសនាពីសំណាក់ក្រុមដែលដើរជួលគេឱ្យធ្វើ ។ ឯកសាររបស់ធនាគារណែនាំ "ការងារអ្នកដឹកនាំក្រុម " ថាតើត្រូវធ្វើការបែបណាជាមួយស្ថាបន័ច្បាប់ថ្នាក់ជាតិដើម្បីបង្វែរមុខដំណែងនៅក្នុងរដ្ឋសភាទៅជាឯកជនភាវូបនីយកម្ម ហើយដាក់ជូននូវការណែនាំថាតើត្រូវធ្វើបែបណាដើម្បីកសាងបណ្តាញស្ថាបន័ច្បាប់ដែលគាំទ្រនូវគោលនយោបាយ ។ ការខិតខំប្រឹងប្រែងទាំងអស់នេះ គឺរំលោភដោយផ្ទាល់ទៅលើមាត្រានៃកិច្ចព្រមព្រៀងផ្ទាល់របស់ធនាគារពិភពលោក ។

វាគឺជាការពិតដែលថាការឃោសនាដែលធនាគារពិភពលោកបានប្រើដើម្បីការពារនូវទំនាក់ទំនងយ៉ាងជិតស្និតរបស់ធនាគារជាមួយនឹងរបបរដ្ឋាភិបាលពុករលួយនានា ។ ឧទាហរណ៍ធំៗមួយចំនួនមានដូចខាងក្រោមនេះ:

- បុរសខ្លាំងជនជាតិប៉េរូឈ្មោះ Alberto Fujimori បានឈ្នះនូវការសរសើររបស់ធនាគារពិលោកដោយការអនុវត្តន៍ដោយគ្មានមេត្តានូវ "ទ្រឹស្តីដ៏តក់ស្លុត" តបកម្មរហូតដល់គាត់បានភៀសខ្លួនទៅប្រទេសជប៉ុននៅក្នុងឆ្នាំ ២០០០ដោយសារតែភាពច្របូកច្របល់បណ្តាលមកពីការបញ្ចេញឱ្យដឹងនូវការលួចបន្លំនូវទឹកប្រាក់ដ៏ច្រើនសន្ធឹកសន្ធាប់និងការទាក់ទងជាច្រើនដើម្បីបង្កើតក្រុមកងទាហ៊ានសំលាប់ ។
- ឧត្តមសេនីយ៍នៃប្រទេសឥណ្ឌូនេស៊ី Suharto បានទទួលលុយ ២៥ពាន់លានដុល្លា ជាលក្ខណៈជំនួយឥតចំណង ដែលភាគច្រើននៃលុយទាំងនោះគឺត្រូវបានលួចបន្លំ នៅខណៈពេលដែលមនុស្សរាប់ពាន់នាក់ត្រូវបានគេសំលាប់រង្គាលនៅទីម័រខាងកើត ។
- មេដឹកនាំផ្តាច់ការនៃប្រទេស Zaire ឈ្មោះ Mobutu Sese Seko (បច្ចុប្បន្ននេះគឺជាសាធារណរដ្ឋប្រជាមានិតកុងហ្គោ) បានទទួលលុយ៦៥០លានដុល្លាពីធនាគារពិភពលោក ទោះបីជាក្រោយពេល

Comment [s1]:

ដែលអ្នកតំណាងស្ថាបន័រូបិយវត្ថុអន្តរជាតិដែលធ្វើការនៅធនាគារឈ្មោះ Erwin Blumenthal ឯប្រទេស Zaire បានរាយការណ៏ថា ប្រាក់ជំនួយឥតសំណងដែលបានទទួលពីពហុស្ថាបន័ផ្សេងៗ ជាធម្មតាគឺចូលទៅដល់ Mobutu ដោយផ្ទាល់ ហើយគ្មានការពិនិត្យជាក់លាក់ណាមួយចំពោះវិធីដែលប្រទេសមួយត្រូវសងលុយទៅស្ថាបន័ទាំងនោះវិញទេ ។ ជាសោកនាថកម្មនោះគឺថា មិនមែនតែធនា-គារ ពិភពលោកតែម្នាក់ឯងនោះទេ ដែលបាននាំឱ្យលុយនោះចូលទៅក្នុងដៃរបស់ Mobutu នៅក្នុងកំឡុងពេលដូចគ្នានោះ ស្ថាបន័រូបិយវត្ថុអន្តរជាតិបានផ្តល់ប្រាក់កម្ចី ៦០០លានដុល្លានិង រដ្ឋាភិបាលលោកខាងលិចក៏បានផ្តល់ប្រាក់ ៣ពាន់លានដុល្លាដល់ Mobutu ផងដែរ ។ Mobutu បានដាក់លុយទៅក្នុងគណនីផ្ទាល់ខ្លួននៅធនាគារប្រទេសស្វីសហើយចំណាយយ៉ាងខ្ជះខ្ជាយទៅលើវិមានរបស់គាត់ ។ នៅពេលដែលគាត់ធ្លាក់ខ្លួន ស្ថាបន័រូបិយវត្ថុអន្តរជាតិបានប្រាប់ដល់រដ្ឋាភិបាលថ្មីរបស់ប្រទេសនេះជាបន្ទាន់ឱ្យរៀបចំគំរោងដើម្បីសងប្រាក់ ១៧ពាន់លានដែលជំពាក់ស្ថាបន័ ។

- របបរើសអើងពូជសាសន៏នៅអាហ្វ្រិកខាងត្បូង មានការពេញចិត្តយ៉ាងខ្លាំងចំពោះការគាំទ្រដោយផ្ទាល់របស់ធនាគារពិភពលោក រហូតទាល់តែការប្រជុំរបស់អង្គការសហប្រជាជាតិបានដាក់នូវការហាមឃាត់ការធ្វើវិនិយោគផ្សេងៗក្រោយឆ្នាំ ១៩៨៣ ប្រាក់ឧបត្ថម្ភបានប្តូរចេញដោយប្រយោលដូចជាតាមរយៈជំនួយឥតសំណងដល់ប្រទេសឡេសូតូ សំរាប់គំរោងធារាសាស្រ្តនៅតំបន់ខ្ពង់រាបនៃប្រទេសឡេសូតូដែលមានសុទ្ធតែអំពើពុករលួយ ក្រោយពេលការកាត់ក្តីក្តាំរឿងដីធ្លីសំរាប់ប្រទេសដ៏តូចបែបនេះ ប្រពន្ធ័តុលាការរបស់ប្រទេសឡេសូតូបានកាត់ក្តីឱ្យអ្នកចាត់ការគំរោងនិងសាជីវកម្មបរទេសជាច្រើនទៀត ដែលចោទប្រកាន់ពីរឿងអំពើពុករលួយ ។ ធនាគារពិភពលោកបានប្រើហេតុផលយ៉ាងល្អបំផុត ដើម្បីជៀសវាងនូវការដាក់ឈ្មោះសាជីវកម្មទាំងអស់នោះទៅក្នុងបញ្ជីសាជីវកម្មមកពីប្រទេសដែលធនាគារបានចុះកុងត្រាជាមួយ ។

រដ្ឋាភិបាលនៃប្រទេសទាំងនេះ បានបន្តដើម្បីសងប្រាក់ដែលជំពាក់បំណុលដែលកើនឡើងក្នុងពេលដែលរបបទាំងអស់នេះកាន់កាប់អំណាច បន្ថែមពីលើការដែលខ្លួនមិនទាំងបានប្រើប្រាស់ថវិកាដើមផងនោះ ។

មុនពេលនៃការមិនដាក់បញ្ចូលនូវការបង្ហាញឱ្យឃើញ នូវភាពច្របូកច្របល់នៃការបន្លំយ៉ាងសន្ធឹកសន្ធាប់នៅឆ្នាំ ២០០១ Enronគឺជាសាជីវកម្មមួយក្នុងចំណោមសាជីវកមជាច្រើន ដែលទាក់ទងយ៉ាងជិតស្និតជាមួយ

ធនាគារពិភពលោក ដែលបានទទួលបានជោគជយ័ក្នុងកុងត្រាដែលមានទឹកប្រាក់ ៧៦១លានដុល្លារបស់ធនាគារពិភពលោកនិងប្រាក់កម្ចីរបស់ធនាគារសំរាប់គំរោងអគ្គិសនីនៅក្នុងប្រទេសមួយចំនួនក្នុងរវាងឆ្នាំ ១៩៩២-២00១ ។ នៅឆ្នាំ ១៩៩៧ ធនាគារពិភពលោកបានផ្តល់ប្រាក់ ៣៧លានដុល្លាដល់ Enron សំរាប់គម្រោងអគ្គិសនីនៅតំបន់សង្គ្រាមកាហ្សា ហើយនៅឆ្នាំ ១៩៩៨ ភ្នាក់ងារធានាពហុវិនិយោគ —MIGA— ជាដៃមួយរបស់ធនាគារពិភពលោក បានផ្តល់ការធានាដល់គំរោងដែលម្ចាស់ការដោយEnron លើផ្នែកអគ្គិសនីនៅប្រទេសប៉ាណាម៉ា ។ នៅឆ្នាំ ២000 MIGA បានចំណាយលុយ១៥លានដុល្លាឱ្យសាជីវកម្ម Enron ឱ្យដើម្បីសងជំងឺចិត្តដល់ការបាត់បង់ប្រាក់ចំណូលដោយសារតែការលុបចោលនូវគំរោងអគ្គិសនីនៅតំបន់យ៉ាវ៉ាខាងកើត គំរោងមួយក្នុងចំណោមគំរោងផ្សេងៗដែលស៊ូហាតូពេញចិត្តជាងគេ ក្រោយពេលដែលជនផ្តាច់ការត្រូវគេទំលាក់ពីតំណែង ។ ការសងជំងឺចិត្តនោះតំណាងឱ្យការធានាតែមួយគត់ដែលMIGA ធ្លាប់បានផ្តល់ឱ្យនៅក្រោមកិច្ចព្រមព្រៀងរបស់វាជាមួយប្រទេសឥណ្ឌូនេស៊ី រដ្ឋាភិបាលនៃប្រទេសឥណ្ឌូនេស៊ីត្រូវបានគេរំពឹងទុកថា សងលុយដល់ MIGA ចំនួន ១៥លានដុល្លា ។ Enron ក៏បានផ្លាស់ប្តូរបុគ្គលិកជាច្រើននាក់ជាមួយធនាគារពិភព-លោកដែលជាផ្នែកមួយនៃកម្មវិធីផ្លាស់ប្តូរបុគ្គលិករបស់គេ ។

ធនាគារពិភពលោកអួតអំពីបញ្ជីនៃក្រុមហ៊ុនធំៗរបស់គេដែលធនាគារប្រកាសថា មិនមានសិទ្ធិក្នុងការធ្វើកុងត្រាហិរញ្ញវត្ថុជាមួយវាដោយសារតែការមិនបានប្រើប្រាស់នូវប្រាក់ឧបត្ថម្ភរបស់ធនាគារកាលពីអតីតកាល ។ ក៏ប៉ុន្តែ ការពិនិត្យមើលឱ្យកាន់តែជិតចំពោះបញ្ជីទាំងនោះបង្ហាញឱ្យឃើញថា វាបញ្ចូលក្រុមហ៊ុនតូចៗនិងបុគ្គលផ្ទាល់ខ្លួនជាច្រើន លើសពីការពិតដែលថា ភាគច្រើននៃកុងត្រាទាំងនោះត្រូវបានផ្តល់ទៅឱ្យដល់សាជីវ-កម្មធំៗ ។ ទោះបីជា Enron ក៏មិនមានឈ្មោះនៅលើបញ្ជីដែរ ។ ធនាគារមិនដែលចាប់ផ្តើមធ្វើការអង្កេតទៅលើការប្រើប្រាស់ថវិការរបស់ធនាគារនៅក្នុង Enron ទេ ក្រៅពីភស្តុតាងយ៉ាងច្បាស់លាស់នៃចំណេះដឹងរបស់ធនាគារចំពោះអំពើពុករលួយនៃការទាក់ទងរបស់ Enron នៅប្រទេសហ្គាតាម៉ាឡា ។

## ការឃោសនា

### ៨. សង្គមស៊ីវិលដើរតួនាទីធំជាងនៅក្នុងការងាររបស់ធនាគារ ។

ការរីកដុះដាលនៃសង្គមស៊ីវិលនៅក្នុងពីរទស្សវត្តន៏ក្រោយនេះ គឺជានិន្នាការដ៏សំខាន់នៅក្នុងការអភិវឌ្ឍន៏អន្តរជាតិ ។ អង្គការសង្គមស៊ីវិលគឺមិនត្រឹមតែមានឥទ្ធិពលលើការជជែកពីបញ្ហាគោលនយោបាយអភិវឌ្ឍន៏របស់ពិភពលោកប៉ុណ្ណោះទេ ក៏ប៉ុន្តែបានក្លាយទៅជាបណ្តាញដ៏សំខាន់សំរាប់ការចែកចាយសេវាសង្គមនិងការបង្កើតកម្មវិធីអភិវឌ្ឍន៏ថ្មីៗ ។ អង្គការសង្គមស៊ីវិលដែលចូលរួមនៅក្នុងគំរោងមូលនិធិរបស់ធនាគារបានកើនឡើងពី២១%នៃគំរោងទាំងអស់នៅក្នុងឆ្នាំ ១៩៩០ ដល់ប្រមាណ ៧២%នៅក្នុងឆ្នាំ ២០០៣ ។ ធនាគារពិភពលោកក៏បង្កើនការគាំទ្រដល់ក្រុមជាច្រើនដូចជាក្រុមសហគមន៏ អង្គការមិនមែនរដ្ឋាភិបាល សហជីព ពាណិជ្ជកម្ម និងអង្គការដែលមានមូលដ្ឋានសាសនា តាមរយៈការចែករំលែកពតិមានយ៉ាងសម្បើម ការបណ្តុះបណ្តាលជំនាញ និងមូលនិធិជំនួយឥតសំណង ។ ជារៀងរាល់ឆ្នាំ ធនាគារផ្តល់មូលនិធិជំនួយឥតសំណងទៅដល់អង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិដើម្បីកសាងឡើងវិញនូវសហគមន៏ដែលបំផ្លិចបំផ្លាញដោយសង្គ្រាម ការអភិវឌ្ឍន៏សេវាកម្មសង្គមនិងសហគមន៏ ។ បុគ្គលិករបស់ធនាគារនៅតាមការិយាល័ក្នុងប្រទេសច្រើនជាង ៧០ ប្រឹក្សានិងសហការជាមួយអង្គការសង្គមស៊ីវិលលើបញ្ហាជាច្រើន តាំងពីការបង្កាជំងឺអេដស៏និងការអភិវឌ្ឍឥណទានខ្នាតតូច ការប្រឆាំងនឹងអំពើពុករលួយនិងការការពារបរិស្ថាន ។”

## ការពិត

អ្វីដែលប្លែកនោះគឺថា ឯកសាររបស់ធនាគារលុបចោលនូវការលើកតំកើងនូវការពិភាក្សាយោបល់របស់សង្គមស៊ីវិល ។ ចាប់ផ្តើមពីឆ្នាំ ១៩៩៩ ស្ថាបន័រូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកបានតំរូវឱ្យប្រទេសខ្ចីប្រាក់ដែលមានចំណូលទាបបង្កើតនូវគំរោងការសេដ្ឋកិច្ច "ឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ" ព្រមគ្នាជាមួយនឹងសង្គមស៊ីវិលដើម្បីដាក់ជូនទៅក្រុមប្រឹក្សារបស់ស្ថាបន័មុនពេលទទួលបានគោលនយោបាយប្រាក់កម្ចីជាមូលដ្ឋាន (កំណែទម្រង់រចនាសម្ព័ន្ធ) ។ កម្មវិធីនេះធ្វើឱ្យមានវិវាទយ៉ាងធំ ដែលត្រូវបានចោទប្រកាន់ថា វាជាការប៉ុនប៉ងក្នុងការចូលរួមជាមួយសង្គមស៊ីវិល ដែលវាបានកើតឡើងមុនដំណើរការនៃច្បាប់ជាតិ ហើយ

លទ្ធផលនៃកិច្ចពិភាក្សាយោបល់គឺកំរត្រូវបានបញ្ចូលទៅក្នុងកម្មវិធីចុងក្រោយណាស់ ។ ការពិត ឥឡូវនេះ វាត្រូវបានគេទទួលស្គាល់ថា ស្ថាបន័រូបិយវត្ថុអន្តរជាតិនិងធនាគារពិភពលោកមិនសង្ស័យថា ឬតាំងចិត្តថាក្រុមសង្គមស៊ីវិលមានលទ្ធផលពិតប្រាកដនៅលើគំរោងម៉ាក្រូសេដ្ឋកិច្ច ដែលជាចំណុចកណ្តាលនៃអ្វីដែលគេ (រហូតមកដល់ការចាប់ផ្តើមនៃកម្មវិធីនេះ) ហៅថា កំណែទម្រង់រចនាសម្ព័ន្ធ ។ ភាពឆ្ងាយពីគ្នារវាងការឃោសនារបស់ធនាគារ (និងស្ថាបន័រូបិយវត្ថុអន្តរជាតិ) នៃ "ការចូលរួម" និងការពិតនោះគឺមិនអាចមើលឃើញឡើង ។

សមាជិករបស់សង្គមស៊ីវិលជាច្រើនដែលបានចូលរួមនៅក្នុងការពិភាក្សាយោបល់របស់ធនាគារពិភពលោកនៅក្រោមដំណើរការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ បានរកឃើញថាបទពិសោធន៍ជាច្រើនគឺមិនទទួលបាននូវការពេញចិត្តទេ ។ Oduor Ong'wen នាយកនៃដំណឹងសេដ្ឋកិច្ចរបស់អាហ្វ្រិកនិងជានាយកនៃក្រុមប្រឹក្សាជាតិនៃអង្គការមិនមែនរដ្ឋាភិបាលកេនយ៉ា បានលើកឡើងបែបនេះៈ "នាពេលមួយដែលប្រជាជនបានអំពាវនាវឡើង ហើយពួកគេបានធ្លាក់ទឹកចិត្តយ៉ាងខ្លាំងដោយសារតែពួកគេគិតថា ចំនុចទាំងអស់នេះនឹងត្រូវសរសេរឡើងដោយការិយាល័យលេខាធិការ ។ ក៏ប៉ុន្តែពួកគេទាំងអស់នេះត្រូវបានផ្តល់ឱ្យនូវគ្រោងការណ៍យ៉ាងចង្អៀតដើម្បីធ្វើដំណើរការ ។ ហេតុដូចនេះហើយ អ្នកនឹងមិនឃើញភាពខុសប្លែកគ្នាច្រើនទេរវាងឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ប្រទេសហ្វីលីពីន បូឡូវៀ កេនយ៉ា ។ ចំនុចនេះធ្វើឱ្យមនុស្សម្នាក់រួចផុតពីកំហុសនៃសញ្ញាដែលចេញពី "ផ្ទះតែមួយ" ។ វាប្រៀបដូចជាការធ្វើពិធីអ្វីមួយៈ លើកឡើងនូវបញ្ហាដូចគ្នាហើយ ទទួលបាននូវការឆ្លើយតបដូចគ្នា ។ នៅពេលដែលអ្នកសួរអំពីវិវត្តន៍ជាក់ស្តែង អ្នកមិនឃើញវាឡើយ ។ ពី ប្រទេសស្រីលង្កាទៅប្រទេសតាន់ហ្សានីយ៉ា នឹងប្រទេសកម្ពុជា ការតវ៉ាអំពីការចូលរួមនៅក្នុងដំណើរនៃឯកសារយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ គឺត្រូវបានសន្និដ្ឋានឱ្យដឹងថាមានលទ្ធផលទទេស្អាត ។

នៅក្នុងការធ្វើផែនការនៃគំរោងជាក់លាក់ទាំងឡាយ ធនាគារពិភពលោកស្ថិតនៅក្នុងកំរិតជ្រើសរើសអង្គការដែលពួកគេនឹងធ្វើការពិភាក្សាយោបល់ជាមួយហើយ តើចំណុចអ្វីខ្លះនៃអនុសាសន៍របស់អង្គការទាំងនោះនឹងត្រូវបានដាក់បញ្ចូល ។ នៅអំឡុងពេលនៃការរៀបចំកម្មវិធីអភិវឌ្ឍន៍ព្រៃឈើរបស់ប្រទេសរ៉ូម៉ានី ធនាគារបានពិភាក្សាយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសរ៉ូម៉ានីតែបីប៉ុណ្ណោះ ហើយមិនមានសូម្បីតែមួយក្នុងចំណោមអង្គការទាំង១៧ ដែលក្រោយមកប្រកាសពីការមិនយល់ស្របរបស់ពួកគេចំពោះកម្មវិធីនេះ ។ កម្មវិធីខ្លះនៃកម្មវិធីបង្កើត "ថ្មី" របស់ធនាគារបានធ្លាក់ទៅក្នុងការទាមទារយ៉ាងខ្លាំងចំពោះការ

ចូលរួមរបស់ធនាគារដែលជាការជ្រៀតជ្រែកទៅក្នុងការងាររបស់សហគមន៏៖  កម្មវិធីថ្មីមួយអំពីមូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុនៅទីម័រខាងកើត (កម្មវិធីដែលបង្ហាញឱ្យឃើញនៅក្នុងចំណុចទី៩ខាងក្រោមនេះ) ជាឧទាហរណ៏បានស្តែងចេញជាលទ្ធផលនៃការតវ៉ាថាធនាគារបានព្យាយាមក្នុងការកែទម្រង់ដំណើរការនៃការធ្វើការសំរេចចិត្តនៅក្នុងសហគមន៏ ឬក៏បង្កើតនូវដំណើរការស្របគ្នាមួយដើម្បីធ្វើវិទង្សនាលើបណ្តាញដែលមានស្រាប់ ។

## ការឃោសនា

៩. "ធនាគារពិភពលោកជួយប្រទេសផ្សេងៗឱ្យរួចពីសង្គ្រាម ។

ថ្មីៗនេះ ធនាគារកំពុងតែសកម្មនៅក្នុង៤០ប្រទេសដែលមានជំលោះយ៉ាងក្តៅគគុក កំពុងធ្វើការជាមួយរដ្ឋាភិបាលនិងដៃគូរមិនមែនរដ្ឋាភិបាល ក្នុងស្រុកនិងអន្តរជាតិ ដើម្បីជួយប្រជាជនដែលបែកខ្ញែកដោយសង្គ្រាម បន្តអភិវឌ្ឍន៏សន្តិភាពនិងបង្កាកុំឱ្យស្ថានការឈានទៅរកអំពើហឹង្សាវិលមកវិញ ។ ការងាររបស់ធនាគារពិភពលោកដោះស្រាយតំរូវការតាមលំដាប់លំដោយ រួមបញ្ចូលទាំងការចាប់ផ្តើមសេដ្ឋកិច្ច ស្ថាបនានិងកសាងប្រពន្ធ័គមនាគមន៏ដែលខូចខាតដោយសារសង្គ្រាម និងស្ថាបន័ដែលជួយសំអាតមីន ដាក់បញ្ចូលអតីតអ្នកធ្វើសង្គ្រាមនិងប្រជាជនដែលរត់ខ្ចាត់ខ្ចាយ ហើយផ្តោតលើកម្មវិធីផ្សេងៗសំរាប់ក្រុមដែលងាយរងគ្រោះថ្នាក់ដូចជាស្ត្រីមេម៉ាយនិងកុមារកំព្រា ។ ធនាគារក៏បានរៀបចំនិងអភិវឌ្ឍន៏វិធីសាស្ត្រជាច្រើននិងការស្រាវជ្រាវដើម្បីវិភាគឱ្យបានកាន់តែប្រសើរនិងស្វែងយល់អំពីប្រភពនៃទំនាស់ ហើយដើម្បីផ្សព្វផ្សាយពីការរីកចំរើនខាងសេដ្ឋកិច្ចនិងការកាត់បន្ថយនៅក្នុងវិធីមួយដែលកាត់បន្ថយនូវអំពើហឹង្សានៅពេលអនាគត ។ ក្នុងចំណោមគំរោងធំៗជាបន្តបន្ទាប់និងកែប្រែជាច្រើន ដែលឧបត្ថម្ភដោយធនាគារគឺជាការដកកងទ័ពចេញពីជួរអ្នកធ្វើសង្គ្រាមនៅក្នុងតំបន់ទន្លេធំៗ ការសាងសង់ប្រពន្ធ័គមនាគមន៏និងការខិតខំប្រឹងប្រែងពង្រឹងភាពម្ចាស់ការដល់សហគមន៏នានានៅក្នុងប្រទេសអាហ្គានីស្ថាន ការដោះស្រាយបញ្ហារបួសផ្លូវចិត្តដោយសារតែសង្គ្រាមរបស់សហគមន៏នានានៅប្រទេសបូស្នាអេហ្សិខូវីណា ការផ្តល់ជំរកដល់កុមារដែលរស់នៅតាមចិញ្ចើមថ្នល់នៅសាធារណរដ្ឋកុងហ្គោ ការកសាងឡើងវិញតាមរយៈការពង្រឹងភាពម្ចាស់ការដល់សហគមន៏នឹងគំរោងគ្រប់គ្រងថ្នាក់មូលដ្ឋាននៅទីម័រខាងកើត និងកម្មវិធីដើម្បីការងារទ្រព្យសម្បត្តិរបស់ប្រជាជនកូឡុំប៊ីដែលបង្កឡើងដោយសារជំលោះ ។"

## ការពិត

**យុទ្ធសាស្ត្ររបស់ធនាគារពិភពលោកនៅប្រទេសនានាដែលទើបតែរួចផុតពីសង្គ្រាមរួមមាន ការធ្វើឯកជនភាវូបនីយកម្ម តបកម្ម និងវិធានការពន្លឿននូវសេរីភាវូបនីយកម្មផ្នែកពាណិជ្ជកម្ម ដូចដែលធនាគារបានដាក់ឡើងនៅគ្រប់ទីកន្លែង ។**

ធនាគារពិភពលោកបានធ្វើការស្វែងរកដោយស្រេកឃ្លានដើម្បីខ្លួនគេបានចូលរួមនៅក្នុងប្រទេសដែលទើបតែរួចផុតពីសង្គ្រាមដូចជាប្រទេសបូស្នា ស៊ើប មូហ្សាមប៊ិក និងរ៉្វាន់ដា ។ ការគិតគូរភាគច្រើនគឺផ្តោតទៅលើតួនាទីរបស់ធនាគារពិភពលោកនៅក្នុងប្រទេសអាហ្គានីស្ថាន និងប្រទេសអ៊ីរ៉ាក់ ។ ឧទាហរណ៍ពីរថ្មីៗនោះគឺទិម័រខាងកើតនិងស្រីលង្កា បានផ្តល់នូវការឃើញមួយភ្លែតនូវវិធីសាស្ត្រដែលធនាគារធ្វើសកម្មភាពនៅក្នុងប្រទេសដែលរងនូវការវិនាសដោយសង្គ្រាមដែលដឹកនាំដោយសហរដ្ឋអាមេរិច ។

ប្រទេសទីម័រខាងកើត ជាប្រទេសមួយដែលក្រីក្រជាងគេនៅទ្វីបអាស៊ី បានប្រឈមមុខនឹងការពុះពាររាប់មិនអស់តាំងពីក្រោយការគ្រប់គ្រងយ៉ាងឃោឃៅរបស់ទាហ៊ានឥណ្ឌូនេស៊ីមកនោះ ។ ដោយយោងទៅតាមប្រជាមតិដោយឯករាជ្យរបស់ប្រទេសទីម័រ ការគ្រប់គ្រងបានធ្វើឱ្យវិនាសនូវហេដ្ឋារចនាសម្ព័ន្ធហើយនាំទៅរកការចាកចោលទីលំនៅរបស់ប្រជាជនជាង៧៥% មុនពេលដែលប្រទេសនេះទទួលបានឯករាជ្យស្របច្បាប់នៅឆ្នាំ ២០០២ ។ យោងទៅតាមបណ្តាញសកម្មភាពរបស់ទីម័រ ដែលជាសកម្មភាពមួយរបស់សហគមន៍អន្តរជាតិដើម្បីឆ្លើយតបទៅការសំលាប់រង្គាលរបស់ប្រទេសនេះ "IFI បានចូលរួមនៅក្នុងការកសាងនូវប្រទេសទីម័រដែលបានប្រើពាក្យពេចន៍ត្រឹមត្រូវ ដែលសង្កត់ធ្ងន់ទៅលើការពង្រឹងភាពម្ចាស់ការ " ការកាត់បន្ថយភាពក្រីក្រនិងចិរភាព ។ ក៏ប៉ុន្តែ នៅទីម័រខាងកើត ដូចជានៅកន្លែងផ្សេងៗដែរ អក្សរដែលសរសេរនៅលើក្រដាសមិនដែលដូចជាការពិតជាក់ស្តែងនោះទេ ។" ការជឿជាក់លើមូលនិធិប្រទេសទីម័រខាងកើត ដែលត្រូវបានផ្ញើរទៅកាន់ប្រទេសនេះនៅខែធ្នូ ឆ្នាំ ១៩៩៩ យ៉ាងឆាប់ក្រោយពេលការមកដល់នៃអ្នកថែរក្សាសន្តិភាពអន្តរជាតិមានដូចជាប្រទេសនេះជាអ្នកជឿលើគំរោងនានារបស់ធនាគារពិភពលោក សាយភាយចេញពី ការជឿជាក់លើមូលនិធិប្រទេសទីម័រខាងកើត ដោយរួមបញ្ចូលទាំងការអភិវឌ្ឍន៍ប្រពន្ធ័គមនាគមន៍ ការងារទឹក ការថែរក្សាសុខភាព និងការអប់រំ ក្នុងចំណោមវិស័យផ្សេងៗទៀត ។ ទោះបីជារដ្ឋាភិបាលបានចាត់ចែងដើម្បីថែរក្សាគោលនយោបាយដែលមិនបង្កើនបំណុលនិងជៀសវាងលក្ខខណ្ឌនានា ក៏ធនាគារបន្តដាក់សំពាធលើរដ្ឋាភិបាលទីម័រខាងកើតឱ្យធ្វើឯកជនភាវូបនីយកម្មលើវិស័យភ្លើងនិងវិស័យប្រៃស័ណី ។

ប្រទេសស្រីលង្កាគឺជាករណីមួយទៀតដែលធនាគារពិភពលោក សំដែងខ្លួនជាឧបការីលើប្រទេសដែលងើបផុតពីសង្គ្រាម មានឱកាសដ៏ប្រសើរបំផុតដើម្បីដាក់ចុះនូវឆន្ទះរបស់ធនាគារលើប្រទេសស្រីលង្កា ប្រជាជនបានធ្វើ

ការប្រឆាំងតបតវិញ ។ នៅក្នុងឆ្នាំ ២០០២ ប្រជាជនស្រីលង្កាជាង ១៥.០០០នាក់បានធ្វើការតវ៉ានៅតាមផ្លូវ ផ្ទាល់ទៅលើកញ្ចប់ផែនការអភិវឌ្ឍន៍ថ្មីដែលតាក់តែងឡើងសំរាប់ប្រទេសនេះ ដែលមានមូលដ្ឋានគ្រឹះលើ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ ដែលគេឱ្យឈ្មោះថា "ភ្ជាប់ទៅនឹងការរីកចំរើន" ។ គ្មានអ្វីដែលគួរឱ្យភ្ញាក់ ផ្អើលនោះទេ មួយរយៈពេលខ្លីក្រោយពេលដែលគំរោងនោះត្រូវបានយល់ស្របដោយរដ្ឋាភិបាលស្រីលង្កា ធនាគារពិភពលោកនិងបងប្អូនរបស់គេគឺស្ថាបន័រូបិយវត្ថុអន្តរជាតិ ដែលមានសន្លឹកច្បាប់ចំនួន ៣៦ដាច់ដោយ ឡែកពីគ្នា ដែលទាំងអស់នោះគឺឆ្លើយតបដោយផ្ទាល់ទៅលើលក្ខខណ្ឌផ្សេងៗដែលបានដាក់ចូលក្នុងយុទ្ធសាស្ត្រ កាត់បន្ថយភាពក្រីក្រ ហើយយោងលើការឆ្លងកាត់នូវមូលនិធិដែលអាចមាន ត្រូវបានផ្ញើទៅកាន់សភាដោយ ធ្វើការពិចារណាជាបន្ទាន់ ។ ដោយសារនេះជាចំនុចសំខាន់លើរបៀបវារៈ ការសេរីរីយ៉ាងលឿននូវការដាក់ឱ្យ ក្លាយជាឯកជននូវរោងចក្រសូត្ររបស់រដ្ឋ ការធានារ៉ាប់រង និងសេវាកម្មសំខាន់ៗដទៃទៀត និងគំរោងកំណែ ទម្រង់ដីធ្លីដែលអំពាវនាវឱ្យមានការផ្លាស់ប្តូរទីលំនៅនៃប្រជាជនចំនួន ១.៨លានគ្រួសារពីដីចំការដ៏តូចៗរបស់ ពួកគេទៅកាន់តំបន់ទីប្រជុំជន ។ សង្គមស៊ីវិលមានលទ្ធភាពក្នុងការទប់ស្កាត់ប្រហែលជា ១/៣នៃច្បាប់ដែល បានលើកឡើង ។

## ការឃោសនា

# ១០ . ធនាគារពិភពលោកកំពុងស្តាប់នូវសំដីរបស់ប្រជាជនក្រីក្រ

"ការសន្ទនាជាមួយប្រជាជន៦០.០០០នាក់ នៅក្នុងបណ្តាប្រទេសចំនួន៦០ រួមជាមួយនឹងការងារប្រចាំថ្ងៃរបស់យើងបានបង្រៀនយើងថា ភាពក្រីក្រគឺវាច្រើនជាងការរកកម្រៃមិនបានគ្រប់គ្រាន់និងកំរិតទាបនៃការអភិវឌ្ឍន៍របស់មនុស្ស ។ វាគឺជាការមិនមានសំលេងលឺដល់អ្នកដទៃនិងភាពគ្មានអំណាច ។ វាគឺជាភាពងាយរងគ្រោះទៅនឹងស្ថានភាពនៃការរំលោភបំពាននិងអំពើពុករលួយ ។ វាគឺជាកង្វះនៃសេរីភាពជាមូលដ្ឋានក្នុងការធ្វើសកម្មភាព ការជ្រើសរើស និងឱកាស ។ ធនាគារជឿជាក់ថា ប្រជាជនដែលរស់នៅក្នុងភាពក្រីក្រមិនគួរត្រូវបានគេចាត់ទុកដូចជាបំណុលនោះទេ តែជាធនធាននិងដៃគូរមួយក្នុងការប្រឆាំងទៅនឹងភាពក្រីក្រ ។ យុទ្ធសាស្ត្រក្នុងការពង្រឹងភាពម្ចាស់ការមួយ ដើម្បីកាត់បន្ថយភាពក្រីក្រគឺដាក់បញ្ចូលជនក្រីក្រនៅចំណុចកណ្តាលនៃការអភិវឌ្ឍន៍ហើយបង្កើតនូវលក្ខខណ្ឌដែលជួយឱ្យបុរសនិងស្ត្រីក្រីក្រក្នុងការទទួលបាននូវការត្រួតត្រាលើជីវិតរបស់ពួកគេ តាមរយៈការទទួលបាននូវពត៌មាន ត្រូវបានបញ្ចូលទៅក្នុងការចូលរួមផ្សេងៗការទទួលខុសត្រូវ និងសមត្ថភាពក្នុងការរៀបចំនៅក្នុងមូលដ្ឋាន ។ បច្ចុប្បន្ននេះ ធនាគារកំពុងតែគាំទ្រគំរោងអភិវឌ្ឍន៍សហគមន៍ដែលមានតំលៃទឹកប្រាក់ច្រើនជាងពីរពាន់លានដុល្លា ។ វិធីផ្សេងៗទៀតក្នុងការជួយវិនិយោគទៅលើការពង្រឹងភាពម្ចាស់ការដល់ប្រជាជនក្រីក្រ រាប់បញ្ចូលទាំងយន្តការទទួលខុសត្រូវក្នុងសង្គមផ្សេងៗនៅក្នុងការដំណើរការនានារបស់ធនាគារ កម្មវិធីសាលារៀនដែលចាត់ចែងដោយសហគមន៍ កំណែទម្រង់ប្រពន្ធ័តុលាការនិងការទទួលបាននូវសេវាកម្មយុត្តិធម៌នានា និងការផ្សព្វផ្សាយនូវកាតពិន្ទុសំរាប់ប្រជាពលរដ្ឋផ្តល់ទូរលេខនៃសេវាកម្មជាមូលដ្ឋានផ្សេងៗ ។"

## ការពិត

**គោលនយោបាយបិទពត៌មានរបស់ធនាគារពិភពលោកនិងរចនាសម្ពន្ធ័រដ្ឋបាលដ៏ស្មុគស្មាញសំរបសំរួលឱ្យមានការទាត់ចោលនូវអត្រាប្រជាជនដែលទទួលរងផលប៉ះពាល់ពីការសន្ទនានិងការចូលរួមផ្សេងៗដែលត្រូវប្រាប់ឱ្យដឹង ។**

ការឃោសនារបស់ធនាគារពិភពលោកដែលថាពួកគេស្តាប់នូវសំដីរបស់ប្រជាជនដែលទីទាល់ក្រគឺជាទំរង់មួយនៃការរីកចំរើនយ៉ាងឆាប់រហ័សជាពិសេសនៅក្នុងការទទួលស្គាល់ របស់ធនាគារថា ឱនភាពនៃការអភិវឌ្ឍន៍គឺត្រូវបានភ្ជាប់ទៅនឹងឱនភាពនៃអំណាច ។ ក៏ប៉ុន្តែ តើធនាគារបានធ្វើអ្វីខ្លះដើម្បីធ្វើការផ្លាស់ប្តូរឱនភាពទាំងនោះ ជាជាងធ្វើឱ្យវាកើនឡើងកាន់តែខ្លាំង?

"តើនរណាម្នាក់អាចលឺយើងនិយាយទេ? "
គឺជាចំណងជើងមួយក្នុងចំណោមចំណងជើងនៃសៀវភៅទាំងបីដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ ២០០០នៅក្នុងសេរីសំដីរបស់ជនក្រីក្ររបស់ធនាគារពិភពលោក អាចហៅបានថា "ហេតុអ្វីបានជាអ្នកមិនស្តាប់សំដីរបស់យើង ?" សៀវភៅទាំងនោះគឺជាលំហាត់មួយក្នុងការ "ព្យាយាមស្គាល់អ្នក" របស់ធនាគារ ដែលទើបតែពេលថ្មីៗបានរកឃើញថាប្រជាជនក្រីក្រអាចជាអចលនទ្រព្យនៃគំរោងការអភិវឌ្ឍន៍ យ៉ាងហោចណាស់សំដែងឱ្យឃើញ ដើម្បីពួកគេទទួលបានផលប្រយោជន៍ ។ ដោយមើលឃើញដូចជាការប្រឹងប្រែងខាងទំនាក់ទំនងសាធារណៈដើម្បីឆ្លើយតបទៅអ្នករិះគន់ដែលចោទ ធនាគារជាមួយនឹងកំហុសនៃការមិនគិតគូរឱ្យម៉ត់ចត់នូវប្រជាជនដែលពួកគេអះអាងថាជាអ្នកទទួលផលចុង ក្រោយនៃកម្មវិធីរបស់គេ សៀវភៅទាំងនោះបែរជាការពន្យល់នូវការពិតនៃការតវ៉ាទាំងនោះទៅវិញ ។ ការពិតគឺគ្រាន់តែជាការទះស្នាដើម្បីធ្វើការសម្ភាសន៍ជាមួយប្រជាជនក្រីក្រដើម្បីបង្ហាញឱ្យគេឃើញ ក្រោយពេល៥០ឆ្នាំនៃការកកើតឡើងរបស់ធនាគារពិភពលោក និងការអនុវត្តន៍មិនល្អទាំងឡាយរបស់វា ។

តាំងពីការបោះពុម្ពសៀវភៅទាំងនោះមក ធនាគារពិភពលោកបានបន្តលើកឡើងពីតំលៃនៃ "ការចូលរួម " ដោយគំរោង-និងគោលនយោបាយ-ដែលប៉ះពាល់ដល់ប្រជាជនក្នុងការសំរេចនូវគំរោងនិងគោលនយោបាយទាំងនោះ ។ ទោះជាយ៉ាងណាក៏ដោយ នៅក្នុងការអនុវត្តន៍ជាក់ស្តែង ធនាគារខ្វះនូវតំលាភាព ជាពិសេសនៅក្នុងគោលនយោបាយបិទពតិមានរបស់គេ ដែលរារាំងប្រជាជនដែលពួកគេអះអាងថាបំរើផលប្រយោជន៍ឱ្យនោះ ឱ្យទទួលបាននូវពតិមានដែលពួកគេត្រូវការក្នុងការធ្វើឱ្យការចូលរួមរបស់ពួកគេមានប្រសិទ្ធិភាព ។ ឯកសារជាច្រើនមិនអាចត្រូវគេរកបានឡើយរហូតទាល់តែផែនការផ្សេងៗត្រូវបានបញ្ចប់ ហើយពេលខ្លះគឺមិនអាចរកបានរហូតទាល់តែក្រុមប្រឹក្សានៅក្នុងធនាគារអនុម័តលើគំរោងទាំងនោះហើយ ។ ឯកសារជាច្រើន រួមទាំងឯកសារដែលជា "កម្មសិទ្ធិរបស់ប្រទេស" គឺអាចរកបានតែជាភាសាអង់គ្លេសរឺភាសារបស់ប្រទេសអឺរ៉ុប

ផ្សេងទៀត ។ គោលនយោបាយបិទពតិមានរបស់ធនាគារពិភពលោកមិនបានធ្វើអ្វីទាំងអស់ដើម្បីលើកតំកើងសមត្ថភាពសំខាន់ៗរបស់ប្រជាជន ក្នុងការចូលរួមនៅក្នុងការធ្វើផែនការនិងការអនុវត្តន៏គំរោងផ្សេងៗរបស់ធនាគារដែលមានផលប៉ះពាល់ដោយផ្ទាល់ទៅលើពួកគេ ដូចជាគំរោងអភិវឌ្ឍន៏ប្រពន្ឋ័គមនាគមន៏ជាដើម ។ ការពិត នៅឆ្នាំ ២០០១ អង្គការជាង ៥០០នាក់មកពីបណ្ដាលប្រទេសផ្សេងៗនៅលើពិភពលោកបានទាមទារ ឱ្យធនាគារបញ្ចេញឯកសារគំរោងជជែកថាបើសិនជាធនាគារអំពាវនាវឱ្យមាន "ការអភិវឌ្ឍន៏ដោយមានការ ចូលរួម " ជាការពិតមែននោះពតិមានដែលទាក់ទងទៅនឹងគំរោងផ្សេងៗត្រូវតែអាចឱ្យសាធារណៈជនរកបាន នៅគ្រប់ជំហ៊ានទាំងអស់នៃគំរោង ដើម្បីឱ្យវាមានប្រសិទ្ធិភាពក្នុងការតាមដាន ។ ការប្រឹងប្រែងដ៏មានប្រសិទ្ធិភាពដើម្បីអំពាវនាវឱ្យមានការកែប្រែដ៏ម៉ត់ចត់នៅក្នុងការប្ដេជ្ញារបស់ធនាគារដើម្បីបកស្រាយឯកសារផ្សេងៗដែលពាក់ពន្ឋ័ជាភាសាដែលងាយយល់សំរាប់ប្រជាជនដែលប៉ះពាល់ ត្រូវបានលើកឡើងនៅដើមឆ្នាំ ២០០៣ ។

បន្ថែមទៅលើការកែប្រែគោលនយោបាយបិទពតិមានរបស់ធនាគារពិភពលោក មានការអវត្តមានដ៏ជាក់ស្តែងនៃការចូលរួមដោយមានលក្ខណៈប្រជាធិបតេយ្យនៅក្នុងរចនាសម្ពន្ឋ័គ្រប់គ្រងផ្ទាល់របស់ធនាគារ ។ សមាជិកទាំង ១៨៤ប្រទេសរបស់ធនាគារពិភពលោកនាពេលបច្ចុប្បន្ននេះ គ្រាន់តែ សហរដ្ឋអាមេរិច ជប៉ុន ចក្រភព អង់គ្លេស បារាំង អាល្លឺម៉ង់គ្រប់គ្រងលើសន្លឹកឆ្នោតជិត ៤០%នៃសន្លឹកឆ្នោតទាំងអស់ ហើយគ្រាន់តែសហរដ្ឋអាមេរិចមួយ គឺកាន់១៥%ទៅហើយ ។ ចំណែកនាយកគ្រប់គ្រងចំនួន២៤ដែលតំណាងឱ្យប្រទេសជាសមាជិក មានតែ២នាក់ទេដែលតំណាងឱ្យបណ្ដាលប្រទេសនៅក្នុងអនុតំបន់សាហារ៉ានៅអាហ្វ្រិក (ដែលមានប្រទេសទាំងអស់ ៤៦ មានន័យថា ២០ប្រទេសមាន១សំលេងឆ្នោត) ហើយប្រទេសទាំងអស់នោះកម្រទទួលបានសំលេងឆ្នោត៥%នៃសំលេងឆ្នោតទាំងមូលណាស់ ។ រចនាសម្ពន្ឋ័នៃឧបសគ្គដើម្បីឈានទៅរកការបង្កើតឱ្យមានការជជែកវែកញែកប្រកបដោយលទ្ធិប្រជាធិបតេយ្យទាំងនេះនៅក្នុងធនាគារពិភពលោកនាំឱ្យមានសំណួរដែលចោទឡើងរវាងថាតើធនាគារមានសមត្ថភាពក្នុងការជជែកដោយជាក់ស្តែងជាមួយអ្នកក្រីក្រដែរឬទេ?

ជាលទ្ធផលនៃការមិនដាក់បញ្ចូលអ្នកក្រីក្រ ឱ្យទទួលបាននូវការពិភាក្សាលើបញ្ហាផ្សេងៗនិងគំរោងដែលប៉ះពាល់ដោយផ្ទាល់លើពួកគេ ជារឿយៗប្រជាជនក្រីក្រទាំងនោះតែងតែប្តូរទៅតវ៉ាជាមួយរដ្ឋាភិបាលរបស់ខ្លួនដែលបានចុះហត្ថលេខាយល់ព្រមទទួលជំនួយ រឺក៏តវ៉ានៅខាងក្រៅកន្លែងប្រជុំផ្សេងៗ នៅពេលដែលស្ថាបន័រូបិយវត្ថុឬធនាគារពិភលោកមកទស្សនៈកិច្ចម្តងៗ ។

ប្រធានធនាគារពិភពលោក James Wolfensohn ដែលបានមកទស្សនាប្រទេស តាន់ហ្សានីញ៉ាកាលពីខែកុម្ភៈត្រូវបានប្រកាសឱ្យដឹងហើយក៏ជាឱកាសដើម្បីស្តាប់នូវបញ្ហារបស់អ្នកក្រីក្រ ក៏ប៉ុន្តែសមាជិកនៃស្ថាបន័សង្គមស៊ីវិលតាន់ហ្សានីញ៉ាគឺមិនគ្រាន់តែមិនត្រូវបានគេអញ្ជើញឱ្យទៅចូលរួមប្រជុំនិងសន្និសិតការសែតជាមួយ Wolfensohnប៉ុណ្ណោះទេ ប៉ុន្តែកំលាំងទព័បំបែកនៅពេលដែលពួកគេព្យាយាមធ្វើបាតុកម្មនៅខាងក្រៅ ។ មានបាតុករ៧នាក់ត្រូវចាប់ខ្លួនហើយវាយធ្វើបាបដោយប៉ូលីស ។ នៅពេលដែលសួរអំពីភាពតាន់តឹងនៅថ្ងៃបន្ទាប់មកនោះ Wolfensohn បានឆ្លើយតបថា "ការពីម្សិលមិញគឺជាថ្ងៃឈប់សំរាក"- ការបង្ហាញឱ្យឃើញនូវការប្រៀបធៀបយ៉ាងច្បាស់ដើម្បីតវ៉ានៅទីក្រុងវ៉ាស៊ីងតោនក្នុងអំឡុងពេលប្រជុំប្រចាំឆ្នាំម្តងៗ ដែលមានអ្នកតវ៉ាច្រើនរហូតដល់ ៣០.០០០នាក់ ។